long beach unified school district



# ថ្នាក់ទីបួន និងទីប្រាំ

## សៀវភៅសកម្មភាពគណិតនៅក្នុងគ្រួសារ

# ក្រសួងអប់រំតំបន់ឡុងប៊ីច
# Long Beach Unified School District
**Christopher Steinhauser, អគ្គនាយក**

# សៀវភៅសកម្មភាពគណិតសាស្ត្រគ្រួសារ
# ថ្នាក់ទី៤និងទី៥
# Fourth & Fifth Grade Family Math Activity Book


រៀបចំឡើងដោយ
Steven Yaffee

ក្រោមការត្រួតពិនិត្យដោយ
Dixie Dawson
អ្នកដឹកនាំកម្មវិធីមុខវិជ្ជាគណិតសាស្ត្រ



បោះពុម្ពដោយ
Office of Curriculum, Instruction, and Professional Development
Office of Special Projects

2006

# ជូនចំពោះមាតាបិតាសិស្សជាទីគោរព

សកម្មភាពនានានៅក្នុងកូនសៀវភៅនេះបានរៀបចំឡើងសំរាប់អ្នកប្រើប្រាស់ដើម្បីកែលំអនិងពង្រឹងកូនអ្នកឲ្យ ឲ្យយល់ពីបញ្ញត្តិនៃគណិតវិទ្យា ពិសេសសង្កត់ធ្ងន់នៅថ្នាក់ទីបួន និងថ្នាក់ទីប្រាំ។
នៅពេលអ្នកណែនាំកូនអ្នកឲ្យធ្វើសកម្មភាពទាំង នេះបញ្ចប់ដោយពេញលេញ នោះអ្នកនឹងកំពុងជួយកូនរបស់អ្នកឲ្យត្រៀមរៀបចំបញ្ញត្តិគណិតវិទ្យាថ្មីៗទៀតដែលបង្ហាញ នៅបណ្ដាឆ្នាំខាងមុខ។ យើងសង្ឃឹមថាអ្នកនឹងរីករាយក្នុងការធ្វើសកម្មភាពលេង និងនិយាយជាមួយកូនអ្នក នៅពេលអ្នក និងកូនស្រាវជ្រាវ ខ្លឹមសារនៃសៀវភៅសកម្មភាពគណិតក្នុងគ្រួសារថ្នាក់ទីបួន និងថ្នាក់ទីប្រាំនេះ។

សកម្មភាពពិតប្រាកដនីមួយៗនៅក្នុងកូនសៀវភៅនេះ តម្រូវឲ្យអ្នកកាត់សន្លឹកទំព័រខ្លះៗ។ ប្រសិនបើអ្នកបិទសន្លឹកទំព័រទាំងនេះ នៅលើប័ណ្ណអក្សរឬក្រដាសក្រាសរឹង (ដូចជាផ្នែកនៃប្រអប់ទទេ) កំណាត់ដែលកាត់ចេញនីមួយៗ មានភាពរឹងមាំនិង ប្រើបានយូរ។ ក្នុងករណីនេះ អ្នកនិងកូនអាចប្រើកំណាត់ទាំងនេះបានម្ដងទៀតដើម្បីឲ្យអ្នកបន្តការអនុវត្ត សកម្មភាពបានច្រើនដង។

សម្ភារៈដែលបានរាយនៅក្នុងទំព័រនីមួយៗតម្រូវឲ្យធ្វើសកម្មភាពទាំងនេះតាមឈ្មោះសកម្មភាពដែលដាក់ផ្ទាល់ចំៗ។ របស់របរនីមួយៗដែលយកមកប្រើក្នុងសកម្មភាពនានា អាចជួយបន្ថែមការសប្បាយរីករាយរបស់កូនអ្នក ដូចជា: គ្រាប់សណ្ដែក ឡេវអាវ កាក់ ខ្មៅដៃពណ៌ ពែង ប្រអប់ទទេ ស្រោមសំបុត្រ ជ័រកាវ ប័ណ្ណអក្សរ ក្រដាស ខ្មៅដៃ បៀ កន្ត្រៃ ស្កុត និងឈើចាក់ធ្មេញ។

ស្តង់ដាខ្លឹមសារគណិតវិទ្យាសំរាប់សាលារៀនសាធារណៈនៅកាលីហ្វ័រនី (California) ត្រូវបានជំរុញអោយមាន សកម្មភាពផ្សេងៗនៅក្នុងកូនសៀវភៅនេះ ហើយបានរាយនៅលើសន្លឹកទំព័រដំបូង នៃសកម្មភាពនីមួយៗ។ រាល់បញ្ជីស្តង់ដាគណិតវិទ្យាថ្នាក់ទីបួន និងថ្នាក់ទីប្រាំមាននៅគ្រប់ទំព័រនៃកូនសៀវភៅនេះ។

# ស្តង់ដាខ្លឹមសារថ្នាក់ទីបួននៅកាលីហ្វ័រនី (California)

ចំនួនស្រដៀង

**1.0** **សិស្សយល់ដឹងពីខ្ទង់តម្លៃលេខចំនួនគត់និងចំនួនទសភាគទៅនឹងចំនួនទសភាគពីរខ្ទង់ និងយល់ពីទំនាក់ទំនងនៃចំនួនគត់និងចំនួនទសភាគទៅនឹងប្រភាគងាយ។ សិស្សប្រើប្រាស់បញ្ញត្តិនៃចំនួនអវិជ្ជមាន ដូចខាងក្រោមនេះ:**

1.1 អាន និងសរសេរចំនួនគត់ជាខ្ទង់លាន។

1.2 រៀបលំដាប់ និងប្រៀបធៀបចំនួនគត់ និងចំនួនទសភាគទៅនឹងចំនួនទសភាគពីរខ្ទង់។

1.3 បង្គត់ចំនួនគត់លេខខ្ទង់លានទៅត្រឹមខ្ទង់ដប់ ខ្ទង់រយ ខ្ទង់ពាន់ ខ្ទង់ម៉ឺន ឬខ្ទង់សែន។

1.4 ធ្វើសេចក្តីសំរេចចិត្តនៅពេលចម្លើយបង្គត់ចំនួនត្រូវបានសួរ និងពន្យល់ពីមូលហេតុអ្វីបានជាចម្លើយនេះសមស្រប។

1.5 ពន្យល់ការបកស្រាយខុសៗគ្នានៃប្រភាគ ឧទាហរណ៏: ប្រភាគជាផ្នែកមួយនៃចំនួនគត់ ជាផ្នែកមួយនៃចំនួនសំណុំ និងវិធីចែកចំនួនគត់និងចំនួនគត់ ពន្យល់សមមូលប្រភាគ(មើលស្តង់ដា 4.0)។

1.6 សរសេរសញ្ញាណប្រភាគ និងចំនួនទសភាគជាខ្ទង់ភាគដប់ ខ្ទង់ភាគរយ និងស្គាល់សមមូលប្រភាគ និងចំនួនទសភាគ សំរាប់សរសេរចំនួនទសភាគជាប្រភាគ និងចំនួនចំរុះ (ឧ.$\frac{1}{2}$ = 0.5 or 0.50; $\frac{7}{4} = 1\frac{3}{4} = 1.75$ )។

1.7 សរសេរប្រភាគដោយគូរផ្ទាំងរូបតាងជាប្រភាគ និងទំនាក់ទំនងប្រភាគទៅនឹងចំនួនទសភាគងាយៗនៅលើបន្ទាត់លេខ។

1.8 ប្រើប្រាស់បញ្ញត្តិនៃចំនួនអវិជ្ជមាន (ឧទា. នៅលើបន្ទាត់លេខ ក្នុងការរាប់លេខ ក្នុងកំដៅសីតុណ្ហភាព "ក្នុងការជំពាក់")។

1.9 កំណត់លើបន្ទាត់ចំនួនទូវទីតាំងទំនាក់ទំនងនៃប្រភាគវិជ្ជមាន ចំនួនចំរុះវិជ្ជមាន និងចំនួនទសភាគវិជ្ជមានទៅនឹងទសភាគពីរខ្ទង់។

**2.0** **សិស្សពង្រីកការយល់ដឹង និងប្រើប្រាស់ចំនួនគត់ ដើម្បីធ្វើប្រមាណវិធីបូក និងដកទសភាគងាយៗ:**

2.1 ប៉ាន់ស្មាន និងគណនាផលបូក ឬភាពខុសគ្នានៃចំនួនគត់ និងចំនួនទសភាគវិជ្ជមានពីរខ្ទង់។

2.2 បង្គត់ចំនួនទសភាគពីរខ្ទង់ទៅជាទសភាគមួយខ្ទង់ឬខិតជិតចំនួនគត់និងគិតឲ្យសមហេតុផលនូវចម្លើយបង្គត់នេះ។

**3.0** **សិស្សដោះស្រាយចំណោទទាក់ទងប្រមាណវិធីបូក ដក គុណ និងចែកចំនួនគត់ និងយល់ពីទំនាក់ទំនងប្រមាណវិធីទាំងនេះ:**

3.1 ស្រាយបំភ្លឺការយល់ដឹង និងលទ្ធភាពប្រើប្រាស់ស្តង់ដាសំណុំក្បួនសំរាប់ប្រមាណវិធីបូកនិងដកនៃចំនួនច្រើនខ្ទង់។

3.2 ស្រាយបំភ្លឺការយល់ដឹង និងលទ្ធភាពប្រើប្រាស់ស្តង់ដាសំណុំក្បួនសំរាប់គុណចំនួនច្រើនខ្ទង់ជាមួយចំនួនពីរខ្ទង់ និងចែកចំនួនច្រើនខ្ទង់ជាមួយចំនួនមួយខ្ទង់ និងប្រើទំនាក់ទំនងរវាងប្រមាណវិធីទាំងនេះដើម្បីសំរួលការគណនា និងត្រួតពិនិត្យលទ្ធផល។

3.3 ដោះស្រាយចំណោទទាក់ទងប្រមាណវិធីគុណចំនួនច្រើនខ្ទង់ជាមួយចំនួនពីរខ្ទង់។

3.4 ដោះស្រាយចំណោទទាក់ទងប្រមាណវិធីចែកចំនួនច្រើនខ្ទង់ជាមួយចំនួនមួយខ្ទង់។

**4.0** **សិស្សយល់ពីរបៀបដាក់ចំនួនគត់តូច:**

4.1 យល់ថាចំនួនគត់ច្រើនអាចបំបែកបានតាមវិធីផ្សេងៗ: (ឧទា.12 = 4 x 3 = 2 x 6 = 2 x 2 x 3) ។

4.2 ចេះដឹងថាចំនួន ដូចជា 2, 3, 5, 7, និង 11 ពុំមានកត្តាច្រើនទេ លើកលែងតែលេខ 1 និងខ្លួនវាហើយចំនួនទាំងនេះហៅថាចំនួនបឋម។

## ពិជគណិត និងអនុគមន៍

**1.0 សិស្សប្រើ និងបកស្រាយអញ្ញាត និមិត្តសញ្ញាគណិតវិទ្យា និងចម្លើយ ដើម្បីសរសេរ និងសំរួលកន្សោម និងឃ្លា។**

1.1 ប្រើអក្សរ ប្រអប់ ឬនិមិត្តសញ្ញាផ្សេងទៀត ដើម្បីតាងលេខណាមួយក្នុងកន្សោមឬសមីការងាយ (ឧទា. ស្រាយបំភ្លឺ ការយល់ដឹង និងប្រើបញ្ញត្តិនៃអញ្ញាត)។

1.2 បកស្រាយ និងវាយតម្លៃកន្សោមគណិតវិទ្យា ដោយប្រើវង់ក្រចក។

1.3 ប្រើវង់ក្រចកដើម្បីចង្អុលប្រាប់ប្រមាណវិធីណាមួយបំពេញដំបូង នៅពេលសរសេរកន្សោមដែលមានទាំងឃ្លាប និងរបាំង និងកន្សោមដែលមានប្រមាណវិធីខុសៗគ្នា។

1.4 ប្រើ និងបកស្រាយរូបមន្ត (ឧទា.ផ្ទៃក្រឡា= បណ្តោយ×ទទឹង ឬផ្ទៃ= ប×ទ)ដើម្បីឆ្លើយនឹងសំណួរអំពីបរិមាណ និងភាពទំនាក់ទំនងរបស់វា។

1.5 យល់ដឹងថាសមីការដូចជា $y = 3x + 5$ គឺជាបញ្ញត្តិមួយដើម្បីកំណត់រកចំនួនទីពីរ ឬតួអង្គទីពីរ នៅពេលចំនួនទីមួយឬតួអង្គទីមួយគេឲ្យ។

**2.0 សិស្សចេះរបៀបដោះស្រាយសមីការ**

2.1 ស្គាល់ និងយល់ដឹងថា សមភាពបូកនឹងសមភាព គឺស្មើគ្នា។

2.2 ស្គាល់ និងយល់ដឹងថា សមភាពគុណនឹងសមភាព គឺស្មើគ្នា។

## រង្វាស់រង្វាល់ និងធរណីមាត្រ

**1.0 សិស្សយល់ដឹងបរិមាត្រ និងផ្ទៃក្រឡាៈ**

1.1 វាស់ផ្ទៃក្រឡាចតុកោណកែងដោយប្រើប្រាស់ឯកតាសមស្រប ដូចជាសង្ទីម៉ែត្រការេ($cm^2$) ម៉ែត្រការេ ($m^2$) គីឡូម៉ែត្រការេ ($km^2$) អ៊ីងការេ($in^2$) យ៉ាតការេ ($yd^2$), ឬម៉ៃលការេ($mi^2$)។

1.2 ទទួលស្គាល់ថាចតុកោណកែងដែលមានផ្ទៃក្រឡាដូចគ្នាអាចមានបរិមាត្រខុសៗគ្នា។

1.3 យល់ដឹងថាចតុកោណកែងដែលមានបរិមាត្រដូចគ្នាអាចមានផ្ទៃក្រឡាខុសៗគ្នា។

1.4 យល់ដឹង និងប្រើរូបមន្តដើម្បីដោះស្រាយចំណោទទាក់ទងនឹងបរិមាត្រ និងផ្ទៃក្រឡាចតុកោណកែង និងការេ។ ប្រើរូបមន្តទាំងនោះដើម្បីរកផ្ទៃក្រឡាដែលមានរូបភាពកាន់តែស្មុកស្មាញដោយចែករូបភាពជាទ្រង់ទ្រាយដើម។

**2.0 សិស្សប្រើក្រដាសមានក្រឡាដែលមានកូអរដោណេពីរទំហំដើម្បីតាងចំណុច និងក្រាបខ្សែ និងរូបភាពងាយៗៈ**

2.1 ដៅចំណុចៗឲ្យឆ្លើយតបទៅនឹងទំនាក់ទំនងជាខ្សែនៅលើក្រដាសក្រាប(ឧទា. ដៅ10ចំណុចនៅលើក្រាបនៃសមីការ $y = 3x$ និងភ្ជាប់ចំណុចទាំងនោះជាខ្សែត្រង់)

2.2 យល់ដឹងថាប្រវែងនៃអង្កត់ខ្សែដេកដូចគ្នានឹងភាពខុសគ្នានៃកូអរដោណេ X

2.3 យល់ដឹងថាប្រវែងនៃអង្កត់ខ្សែឈរដូចគ្នានឹងភាពខុសគ្នានៃកូអរដោណេ Y

**3.0 សិស្សស្រាយបំភ្លឺការយល់ដឹងពីវត្ថុធរណីមាត្រសូលីត និងប្លង់ និងប្រើចំណេះដឹងនេះដើម្បីបង្ហាញពីទំនាក់ទំនង និងដោះស្រាយ ចំណោទៈ**

3.1 កំណត់រកបន្ទាត់ស្របគ្នា និងបន្ទាត់កែងគ្នា។

3.2 កំណត់រកកាំ និងអង្កត់ផ្ចិតនៃរង្វង់។

3.3 កំណត់រករូបភាពដូចនិងប៉ុនគ្នា

3.4 កំណត់រកឲ្យឃើញភាពពីរស៊ីមេទ្រីគ្នា និងត្រួតស៊ីគ្នា។

3.5 ចេះនិយមន័យនៃមុំកែង មុំស្រួច និងមុំទាល។ យល់ថាមុំ 90°, 180°,270° និង 360° ផ្តុំបានជាប្រភាគ $\frac{1}{4}$, $\frac{1}{2}$, $\frac{3}{4}$ និងទាំងមូល (ស្មើនឹង1)។

3.6 សំឡឹងមើលឃើញ ពណ៌នា និងធ្វើគំរូធរណីមាត្រសូលីត (ឧទា. ព្រីស ពីរ៉ាមីត)ទាក់ទិនទៅនឹងចំនួន និងទ្រង់ទ្រាយនៃមុខ គែម និងកំពូលសូលីត បកស្រាយតំណាងពីរទំហំនៃវត្ថុដែលមានបីទំហំ និងគូរគំរូតាង (ផ្នែកមុខ)ដោយធ្វើយ៉ាងណានៅពេលកាត់រូបសូលីត និងបត់នោះនឹងបានជារាងសូលីតគំរូតែម្តង។

3.7 ចេះនិយមន័យនៃត្រីកោណផ្សេងៗ(ឧទា.ត្រីកោណសម័ង្ស ត្រីកោណសមបាត វង្វាស់មុំ)និងកំណត់រកការសន្មត របស់វា។

3.8 ដឹងនិយមន័យនៃចតុកោណផ្សេងៗ (ឧទា.ចតុកោណស្មើ ការេ ចតុកោណកែង ប្រឡេឡូក្រាម ចតុកោណពញ្ញយ)។

## ស្ថិតិ ការវិភាគទិន្នន័យ និងប្រូបាប៊ីលីតេ

**1.0 សិស្សចាត់ថែង បង្ហាញ និងបកស្រាយទិន្នន័យជាប្រភេទ និងជាលេខ និងទំនាក់ទំនងច្បាស់លាស់ពីរបកគំហើញរបស់ពួកគេ:**

1.1 បង្កើតសំណួរអង្កេត ប្រមូលនិងតាងទិន្នន័យនៅលើបន្ទាត់ចំនួនជាប្រព័ន្ធ និងរៀបចំសំរបសំរួលក្រាប តារាង និងឆាត។

1.2 កំណត់រកម៉ូតសំណុំនៃប្រភេទទិន្នន័យនិងម៉ូតមេដ្យាននិងចំនួនពិតប្រាកដផ្សេងទៀតសំរាប់សំណុំទិន្នន័យ ជាលេខ។

1.3 បកស្រាយក្រាបទិន្នន័យមួយ និងពីរអថេរដើម្បីឆ្លើយនឹងសំណួរអំពីស្ថានភាព។

**2.0 សិស្សធ្វើការប្រមើលទុកនូវស្ថានភាពប្រូបាប៊ីលីតេងាយៗ។**

2.1 បង្ហាញគ្រប់លទ្ធភាពនៃលទ្ធផលសំរេចសំរាប់ស្ថានភាពប្រូបាប៊ីលីតេងាយក្នុងមធ្យោបាយចាត់ចែងមួយ (ឧទា. តារាង ក្រឡាសំណាញ់ ដ្យាក្រាមចំនួនបី )។

2.2 បញ្ជាក់លទ្ធផលសំរេចនៃស្ថានភាពប្រូបាប៊ីលីតេពិសោធន៏ដោយវាចារ និងជាលេខ (ឧទា. 3 ភាគ 4; $\frac{3}{4}$ )។

## គណិតវិទ្យាបែបពិចារណា

**1.0 សិស្សធ្វើការសំរេចចិត្តអំពីរបៀបដោះស្រាយបញ្ហា:**

1.1 វិភាគបញ្ហាដោយកំណត់រកភាពទាក់ទង វែកញែកព៏មានដែលទាក់ទងដោយផ្តើមចេញមកពីព័ត៏មានដែលមិនទាក់ទង រៀបលំដាប់បន្តបន្ទាប់ និងឲ្យអាទិភាពព័ត៏មាន និងសង្កេតលំនាំ។

1.2 កំណត់ពេលវេលា និងរបៀបបំបែកបញ្ហាជាផ្នែកងាយៗ។

**2.0 សិស្សប្រើយុទ្ធសាស្ត្រ បំណិន និងបញ្ញត្តិក្នុងការរកដំណោះស្រាយ:**

2.1 ប្រើការប៉ាន់ស្មានដើម្បីផ្ទៀងផ្ទាត់ការពិចារណានៃលទ្ធផលដែលបានគណនា។

2.2 អនុវត្តយុទ្ធសាស្ត្រ និងលទ្ធផល ផ្តើមចេញពីបញ្ហាងាយៗទៅបញ្ហាកាន់តែស្មុកស្មាញ។

2.3 ប្រើវិធីផ្សេងៗ ដូចជា ពាក្យ ចំនួន និមិត្តសញ្ញា ឆាត ក្រាប តារាង ដ្យាក្រាម និងម៉ូដែល ដើម្បីពន្យល់គណិតវិទ្យាបែបពិចារណា។

2.4 បញ្ជាក់ដំណោះស្រាយឲ្យច្បាស់លាស់និងសមហេតុផល ដោយប្រើសញ្ញាណគណិតវិទ្យានិងពាក្យបច្ចេកទេសសមស្រប និងភាសាច្បាស់លាស់ គាំទ្រដំណោះស្រាយប្រកបដោយភស្តុតាងជាក់ស្តែងទាំងវាចារ និងទាំងពាក្យនិមិត្តសញ្ញា។

2.5 ចង្អុលប្រាប់គុណសម្បត្តិដែលទាក់ទងនឹងដំណោះស្រាយប្រហាក់ប្រហែល និងដំណោះស្រាយចំៗនៃបញ្ហា និងផ្តល់ចម្លើយតាមកំរិតជាក់លាក់នៃភាពត្រឹមត្រូវ។

2.6 ធ្វើការគណនាឲ្យខ្ចីជាក់លាក់ និងត្រួតពិនិត្យសុពលភាពនៃលទ្ធផលនៃបរិបទបញ្ហា។

.

**3.0 សិស្សឈានទៅគិតបញ្ហាពិសេសខាងមុខដោយសិក្សាទូទៅនូវដំណោះស្រាយផ្សេងទៀតៈ**

3.1 វាយតម្លៃនៃដំណោះស្រាយនៅក្នុងបរិបទនៃស្ថានភាពដើមប្រកបដោយភាពពិចារណា។

3.2 កត់វិធីសាស្ត្រនៃការទាញយកដំណោះស្រាយ និងស្រាយបំភ្លឺការយល់ដឹងបញ្ញត្តិនៃការទាញយកបញ្ហាដោយដោះស្រាយបញ្ហាស្រដៀងគ្នា។

3.3 អភិវឌ្ឍន៍ការធ្វើអោយមានលក្ខណៈទូទៅនៃលទ្ធផលដែលទទួលបាន និងអនុវត្តលទ្ធផលដែលទទួលបាននោះក្នុងកាលៈទេសៈផ្សេងទៀត។

# ស្តង់ដាខ្លឹមសារថ្នាក់ទីប្រាំនៅកាលីហ្វ័រនី (California )

**California Content Standards for Grade Five**

## ចំនួនស្រដៀង **Number Sense**

**1.0** **សិស្សគណនាចំនួនធំបំផុត និងតូចបំផុត លេខគត់វិជ្ជមាន ចំនួនទសភាគ និងប្រភាគ និងយល់ដឹងពីភាពទាក់ទង រវាងចំនួនទសភាគ ប្រភាគ និងភាគរយ។ ពួកគេយល់ពីទំហំដែលទាក់ទងនឹងចំនួនៈ**

1.1 ប៉ាន់ស្មាន បង្គត់ និងប្រើប្រាស់ចំនួនធំបំផុត (ឧទា.ខ្ទង់លាន) និងចំនួនតូចបំផុត(ឧទា.ខ្ទង់ពាន់)។

1.2 បកស្រាយភាគរយដែលជាផ្នែកមួយនៃមួយរយ រកសមមូលទសភាគ និងភាគរយជាប្រភាគរួម និងពន្យល់ថាហេតុអ្វីបានជាមានតម្លៃដូចគ្នា គណនាភាគរយនៃចំនួនគត់។compute a given percent of a whole number.

1.3 យល់ដឹង និងគណនាឥទ្ធិពលលេខគត់វិជ្ជមាននៃលេខគត់មិនអវិជ្ជមាន រកឧទាហរណ៍ដូចបានរំលឹកនៅក្នុងប្រមាណវិធីគុណ។

1.4 កំណត់កត្តាបឋមនៃចំនួនទាំងអស់តាមរយៈលេខ 50 និងសរសេរចំនួនដែលបានពីកត្តាបឋមដោយប្រើសន្ទស្សន៍ដើម្បីបង្ហាញផលគុណកត្តាបឋម (ឧទា. $24 = 2 \times 2 \times 2 \times 3 = 2^3 \times 3$)។

1.5 កំណត់រក និងតាងចំនួនទសភាគជាបន្ទាត់ ប្រភាគ ចំនួនចំរុះ និងលេខគត់វិជ្ជមាន និងអវិជ្ជមាន។

**2.0** **សិស្សធ្វើការគណនា និងដោះស្រាយចំណោទទាក់ទងទៅនឹងប្រមាណវិធីបូក វិធីដក និងប្រមាណវិធីគុណ និងវិធីចែកទសភាគ និងប្រភាគងាយៗ :**

2.1 វិធីបូក ដក គុណ និងចែកចំនួនទសភាគ បូកលេខគត់អវិជ្ជមាន ដកលេខគត់វិជ្ជមានពីលេខគត់អវិជ្ជមាន និងផ្ទៀងផ្ទាត់លទ្ធផលប្រកបដោយភាពពិចារណា។

2.2 ស្រាយបំភ្លឺវិធីចែកដោយប៉ិនប្រសប់ រួមមានចែកចំនួនទសភាគវិជ្ជមាន និងចែកចំនួនច្រើនខ្ទង់។

2.3 ដោះស្រាយចំណោទងាយៗ រួមមានចំណោទដែលលើកឡើងពីស្ថានភាពរូបី ទាក់ទងនឹងវិធីបូក ដកនៃប្រភាគ និងចំនួនចំរុះ (ភាគបែងដូចគ្នា និងមិនដូចគ្នានៃ 20 ឬតិចជាង) និងបញ្ជាក់ចម្លើយជាទំរង់ងាយបំផុត។

2.4 យល់ដឹងបញ្ញត្តិនៃប្រមាណវិធីគុណ និងវិធីចែកប្រភាគ។

2.5 គណនា និងធ្វើប្រមាណវិធីគុណ និងចែកប្រភាគងាយ និងអនុវត្តនីតិវិធីទាំងនេះដើម្បីដោះស្រាយចំណោទ។

## ពិជគណិត និងអនុគមន៍ **Algebra and Functions**

**1.0** **សិស្សប្រើអញ្ញាតក្នុងកន្សោមងាយៗ គណនាតម្លៃអញ្ញាតជាក់លាក់ក្នុងកន្សោម ដៅចំណុច និងបកស្រាយលទ្ធផល :**

1.1 ប្រើព័ត៌មានដែលបានមកពីក្រាប ឬសមីការសំរាប់ឆ្លើយនឹងសំណួរអំពីស្ថានភាពចំណោទ។

1.2 ប្រើអក្សរតាងចំនួនមិនស្គាល់ សរសេរនិងវាយតម្លៃកន្សោមពីជគណិតងាយៗដែលមានមួយអញ្ញាតដាក់ជំនួស។

1.3 ស្គាល់ និងប្រើអញ្ញាតរកឃើញមកជំនួសក្នុងសមីការ និងកន្សោមពីជគណិត។

1.4 កំណត់រក និងសង់ក្រាបក្នុងប្លង់កូអរដោណេនៃចតុកោណ។

1.5 ដោះស្រាយចំណោទទាក់ទងនឹងអនុគមន៍ខ្សែដែលមានតម្លៃលេខគត់ សរសេរសមីការ និងសង់ក្រាបដែលមានលទ្ធផលលំដាប់គូនៃលេខគត់នៅលើក្រដាសក្រឡា។

## រង្វាស់រង្វាល់ និងធរណីមាត្រ Measurement and Geometry

**1.0** **សិស្សយល់ដឹង និងគណនាមាឌ និងផ្ទៃក្រឡានៃវត្ថុងាយៗ :**

1.1 ប្រើរូបមន្ត និងទាញរកផ្ទៃក្រឡានៃត្រីកោណ និងប្រលេឡូក្រាម ដោយប្រៀបធៀបរូបមន្តនេះទៅនឹងរូបមន្តផ្ទៃក្រឡាចតុកោណកែង (ឧទា. ត្រីកោណពីរដូចគ្នាបង្កើតបានជាប្រលេឡូក្រាមដែលមានផ្ទៃពីរដង។ ប្រលេឡូក្រាមត្រូវបានប្រៀបធៀបជាមួយចតុកោណកែង ដែលមានផ្ទៃក្រឡាដូចគ្នា ដោយកាត់និងបិទត្រីកោណកែង នៅលើប្រលេឡូក្រាម )។

1.2 សង់គូបនិងប្រអប់ចតុកោណកែងដែលមានគំរូពីរទំហំ និងប្រើគំរូនេះដើម្បីគណនាផ្ទៃក្រឡានៃវត្ថុទាំងនេះ។

1.3 យល់ដឹងបញ្ញត្តិនៃមាឌ និងប្រើឯកតានីមួយៗសមស្របសំរាប់វាស់វែងប្រព័ន្ធរួម(ឧទា.សង់ទីម៉ែត្រគូប-$cm^3$ ម៉ែត្រគូប-$m^3$ អ៊ិនគូប-$in^3$ យ៉ាតគូប-$yd^3$ ដើម្បីគណនាមាឌនៃសូលីតចតុកោណកែង )។

1.4 រកភាពខុសគ្នារវាង វត្ថុពីរ-បីទំហំ និងប្រើឯកតានីមួយៗសមស្របសំរាប់វាស់វែង។

**2.0** **សិស្សកំណត់រក ពណ៌នា និងចំណាត់ថ្នាក់នូវចម្លើយនិងភាពទាក់ទងរវាងរូបធរណីមាត្រសូលីត និងប្លង់ :**

2.1 វាស់ កំណត់រក និងគូរមុំ បន្ទាត់កែង និងបន្ទាត់ស្រប ចតុកោណកែង និងត្រីកោណ ដោយប្រើឧបករណ៏សមស្រប (ឧទា. ចម្រៀកទ្រនង់ បន្ទាត់ ដែកឈាន រ៉ាប៉័រ គ្រឿងទន់សំរាប់គូរ)។

2.2 យល់ដឹងថា ផលបូកមុំនៃត្រីកោណណាមួយក៏ដោយ មានមុំ 180° និងផលបូកមុំនៃចតុកោណណាក៏ដោយមានមុំ 180° និងប្រើព័ត៌មាននេះដើម្បីដោះស្រាយចំណោទ។

2.3 សំឡឹងមើល និងគូរការមើលឃើញវត្ថុពីរទំហំនៃវត្ថុបីទំហំដែលធ្វើពីសូលីតចតុកោណកែង។

## ស្ថិតិ ការវិភាគទិន្នន័យ និងប្រូបាប៊ីលីតេ Statistics, Data Analysis, and Probability

**1.0** **សិស្សដាក់តាំងបង្ហាញ វិភាគ ប្រៀបធៀប និងបកស្រាយសំណុំទិន្នន័យផ្សេងៗ រួមមានសំណុំទិន្នន័យទំហំខុសៗគ្នា:**

1.1 ស្គាល់បញ្ញត្តិនៃ មីន មេដ្យាន និងម៉ូតគណនា និងប្រៀបធៀបឧទាហរណ៏ងាយៗដើម្បីបង្ហាញពីភាពខុសៗគ្នា។

1.2 ចាត់ចែង និងដាក់តាំងបង្ហាញទិន្នន័យមួយអញ្ញាតនៅក្នុងក្រាបសមស្រប និងការតាង(ឧទា.ឆាតសរសរក្រាបផ្ចិត)។

1.3 ប្រើប្រភាគ និងភាគរយ ដើម្បីប្រៀបធៀបសំណុំទិន្នន័យទំហំខុសៗគ្នា។

1.4 កំណត់រកលំដាប់គូនៃទិន្នន័យពីក្រាប និងបកស្រាយន័យនៃទិន្នន័យទាក់ទិននឹងស្ថានភាពដែលបង្ហាញនៅលើក្រាប។

1.5 ស្គាល់ពីរបៀបសរសេរលំដាប់គូត្រឹមត្រូវ ឧទាហរណ៏ (x, y) ។

## គណិតវិទ្យាបែបពិចារណា

**1.0** **សិស្សធ្វើការសំរេចចិត្តអំពីរបៀបដោះស្រាយបញ្ហា:**

1.1 វិភាគបញ្ហាដោយកំណត់រកភាពទាក់ទង វែកញែកពឹមានដែលទាក់ទងដោយផ្តើមចេញមកពីព័ត៌មានដែលមិនទាក់ទង រៀបលំដាប់បន្តបន្ទាប់ និងឲ្យអាទិភាពព័ត៌មាន និងសង្កេតលំនាំ។

1.2 កំណត់ពេលវេលា និងរបៀបបំបែកបញ្ហាជាផ្នែកងាយៗ។

**2.0** **សិស្សប្រើយុទ្ធសាស្ត្រ បំណិន និងបញ្ញត្តិក្នុងការរកដំណោះស្រាយ:**

2.1 ប្រើការប៉ាន់ស្មានដើម្បីផ្ទៀងផ្ទាត់ការពិចារណានៃលទ្ធផលដែលបានគណនា។

2.2 អនុវត្តយុទ្ធសាស្ត្រ និងលទ្ធផល ផ្តើមចេញពីបញ្ហាងាយៗទៅបញ្ហាកាន់តែស្មុកស្មាញ។

2.3 ប្រើវិធីផ្សេងៗ ដូចជា ពាក្យ ចំនួន និមិត្តសញ្ញា ឆាត ក្រាប តារាង ដ្យាក្រាម និងម៉ូដែល ដើម្បីពន្យល់គណិតវិទ្យាបែបពិចារណា។

2.4 បញ្ជាក់ដំណោះស្រាយឲ្យច្បាស់លាស់និងសមហេតុផល ដោយប្រើសញ្ញាណគណិតវិទ្យានិងពាក្យបច្ចេកទេសសមស្រប និងភាសាច្បាស់លាស់ គាំទ្រដំណោះស្រាយប្រកបដោយភស្តុតាងជាក់ស្តែងទាំងវាចារ និងទាំងពាក្យនិមិត្តសញ្ញា។

2.5 ចង្អុលប្រាប់គុណសម្បត្តិដែលទាក់ទងនឹងដំណោះស្រាយប្រហាក់ប្រហែល និងដំណោះស្រាយចំៗនៃបញ្ហា និងផ្តល់ចម្លើយតាមកំរិតជាក់លាក់នៃភាពត្រឹមត្រូវ។

2.6 ធ្វើការគណនាឲ្យខ្ញីជាក់លាក់ និងត្រួតពិនិត្យសុពលភាពនៃលទ្ធផលពីបរិបទនៃបញ្ហា។

**3.0 សិស្សឈានទៅគិតបញ្ហាពិសេសខាងមុខដោយសិក្សាទូទៅនូវដំណោះស្រាយផ្សេងទៀតៈ**

3.1 វាយតម្លៃនៃដំណោះស្រាយនៅក្នុងបរិបទនៃស្ថានភាពដើមប្រកបដោយភាពពិចារណា។

3.2 កត់វិធីសាស្ត្រនៃការទាញយកដំណោះស្រាយ និងស្រាយបំភ្លឺការយល់ដឹងបញ្ញត្តិនៃការទាញយកបញ្ហាដោយដោះស្រាយបញ្ហាស្រដៀងគ្នា។

3.3 អភិវឌ្ឍន៏ការធ្វើអោយមានលក្ខណៈទូទៅនៃលទ្ធផលដែលទទួលបាន និងអនុវត្តលទ្ធផលដែលទទួលបាននោះក្នុងកាលៈទេសៈផ្សេងទៀត។

**ស្តង់ដាថ្នាក់ទីបួនៈ ចំនួន 1.2**

សិស្សរៀបលំដាប់ និងប្រៀបធៀបចំនួនគត់ និងចំនួនទសភាគទៅនឹងចំនួនទសភាគ២ខ្ទង់។

**ស្តង់ដាថ្នាក់ទី៥ៈ ចំនួន 1.1**

សិស្សប៉ាន់ស្មាន បង្គត់ និង ប្រើចំនួនធំបំផុត (ឧទា.ខ្ទង់លាន) និងចំនួនតូចបំផុត (ឧទា.ខ្ទង់ពាន់)

# សង់ចំនួនធំបំផុត

សម្ភារៈបង្រៀនៈ ស្តង់ដាតុលេងបៀ ផ្ទាំងក្រដាសមានកំណត់តម្លៃលេខ

វត្ថុនៃល្បែងនេះគឺសង់ចំនួនគត់ធំបំផុតដែលមានចំនួនទសភាគ២ខ្ទង់។អ្នកលេងពី២ទៅ៨នាក់អាចលេងល្បែងនេះ (ប៉ុន្តែល្បែងនេះបើលេងប្រកបដោយសុខស្រួលបំផុតនោះគឺឲ្យមានអ្នកលេងពី ២-៣ ឬ៤នាក់ប៉ុណ្ណោះ)។

នៅលើស្តង់ដាតុលេងបៀដែលមានបៀចំនួន 52 សន្លឹក ត្រូវដកសន្លឹកបៀចេញរូបស្តេចប្រុស ស្តេចស្រី កំឡោះ និងសន្លឹក 10។ រូបអាត់តំណាងលេខមួយ(1)។ចំណែកឯសន្លឹកបៀលេខផ្សេងៗទៀតត្រូវតាងដោយ តម្លៃលេខនៃសន្លឹកបៀ។

នៅលើផ្ទាំងក្រដាសដោយឡែក ធ្វើផ្ទាំងតម្លៃលេខឲ្យស្រដៀងគ្នាដូចខាងលើ ប៉ុន្តែត្រូវធ្វើក្ងឡោនឲ្យទូលាយគ្រប់គ្រាន់ ដើម្បីងាយស្រួលដាក់សន្លឹកបៀ។

## ផ្ទាំងតម្លៃលេខ

| ខ្ទង់ដប់ | ខ្ទង់រាយ | • | ខ្ទង់ភាគដប់ | ខ្ទង់ភាគរយ | ខ្ទង់ភាគពាន់ |
|---|---|---|---|---|---|
| | | | | | |

សាប់បៀហើយដាក់បៀចុះនៅមុខអ្នកលេង។ អ្នកលេងទីមួយ គូរសន្លឹកបៀ១នៅលើខ្ទង់ដប់ ខ្ទង់រាយ ខ្ទង់ភាគដប់ ខ្ទង់ភាគរយឬខ្ទង់ភាគពាន់។ ត្រូវចងចាំថាវត្ថុនៃល្បែងនេះគឺសង់ចំនួនធំបំផុតតាមលទ្ធភាពអាចធ្វើបាន។ ការលេងបន្តទៅខាងឆ្វេងដោយឲ្យអ្នកលេងម្នាក់ៗដាក់សន្លឹកបៀនៅលើផ្ទាំងក្រដាសដែលមាន កំណត់តម្លៃនៅលើនោះ។ អ្នកលេងដែលមានលេខធំជាងគេបំផុតឈ្នះក្នុងជុំនេះ។ អ្នកលេងទីមួយដែលមាន លេខធំជាងគេបំផុតនោះគឺឈ្នះល្បែង។ ដើម្បីឈ្នះល្បែងនេះអ្នកលេងទីមួយ ត្រូវលេងឲ្យឈ្នះប្រាំជុំល្បែង។

បំរែបំរួលទីមួយៈ គ្របក្ងឡោនខ្ទង់រយ និង/ឬ ខ្ទង់ពាន់ ហើយអោយកូនណាមួយដែលមានលក្ខណៈលំបាក ក្នុងការទទួលយកបញ្ញតិនៃចំនួនទសភាគ អោយប្រើប្រាស់តែខ្ទងដប់ប៉ុណ្ណោះ។

បំរែបំរួលទីពីរៈ លេងល្បែងនេះដូចវិធីខាងលើ ប៉ុន្តែឥឡូវនេះអ្នកដែលឈ្នះ គឺអ្នកលេងដែលសង់ចំនួន តូចបំផុត។

បំរែបំរួលទីបីៈ នៅក្នុងបំរែបំរួលនេះ កំណត់ “ចំនួនដៅទុក” ដូចជា 11.99, 12.34, 24.51, 33.33, ។ល។ អ្នកឈ្នះគឺអ្នកដែលសង់ចំនួនខិតទៅរកជិតបំផុតនៃចំនួនដៅទុក។

**កំណត់ចំណាំៈ** សន្លឹកបៀ សន្ទស្សន៍3x5 អាចដាក់ជំនួសសំរាប់តុលេងបៀ។ មុននឹងចាប់ផ្តើមលេង ត្រូវសរសេរលេខ 1 នៅលើ សន្លឹកបៀទីមួយៗដែលមានចំនួនបួនសន្លឹក។ បន្តការលេងនេះរហូតដល់អ្នកអាចបង្កើតបានសន្លឹកបៀបួនឈុតដែលមានគ្រប់លេខ គឺ 1, 2, 3, 4, 5, 6, 7, 8, និង 9។ ឲ្យកូនអ្នកអានលេខឲ្យឮៗ។ ឧទាហរណ៍លេខ 98.76 អានថា “កៅសិបប្រាំបី និងចិតសិបប្រាំមួយទសភាគភាគរយ”។ សង្កត់ធ្ងន់លើពាក្យ “និង” សំគាល់ចំនុចទសភាគ។ កុំយល់ព្រមឲ្យថា “ កៅសិបប្រាំបីចុចចិតសិបប្រាំមួយ ”។ ឲ្យកូនសរសេរ និងរៀបលំដាប់ចំនួនទាំងអស់ដែលបានបង្កើត ពីចំនួនធំបំផុតទៅចំនួនតូចបំផុត ហើយប្រាប់អ្នកអ្វីដែលគេយល់គេធ្វើត្រូវ។

# ឆាតខ្ទង់តម្លៃលេខទសភាគ **Decimal Place Value Chart**

## ខ្ទង់ពាន់

| ខ្ទង់ដប់ **(10)** | ខ្ទង់រាយ **(1)** | ● | ខ្ទង់ភាគដប់ **(.1)** | ខ្ទង់ភាគរយ **(.01)** | ខ្ទង់ភាគពាន់ **(.001)** |
|---|---|---|---|---|---|
| | | | | | |

**ស្តង់ដាថ្នាក់ទីបួន : ចំនួន 3.4**

សិស្សដោះស្រាយចំណោទទាក់ទងប្រមាណវិធីចែកចំនួនច្រើនខ្ទង់ជាមួយនឹងចំនួនមួយខ្ទង់។

**ស្តង់ដាថ្នាក់ទីប្រាំ : ចំនួន 2.2**

សិស្សស្រាយបំភ្លឺប្រមាណវិធីចែកយ៉ាងស្ទាត់ជំនាញ។

# លទ្ធភាពអាចចែកដាច់

**សម្ភារៈបង្រៀន :** ស្តង់ដាតុលេងបៀ ខ្មៅដៃ ប៊ិច ម៉ាស៊ីនគិតលេខ

វត្ថុនៃល្បែងនេះសំរាប់អ្នកលេងពីរនាក់ ចាប់យកសន្លឹកបៀឲ្យបានច្រើនបំផុតតាមការកំណត់ក្បួនចែកឲ្យបាន ត្រឹមត្រូវ។

ដកសន្លឹកបៀរូបស្តេចប្រុស កំឡោះ ស្តេចស្រី និងសន្លឹកដប់ចេញពីតុ ទុកតែ 36 សន្លឹកប៉ុណ្ណោះ។ សន្លឹក អាត់តាងលេខ 1 និងសន្លឹកផ្សេងៗទៀតលេខ 2-9 តាងតម្លៃលេខដែលមានលើសន្លឹកបៀនោះ។

សាប់បៀ ហើយចែកម្នាក់ៗប្រាំសន្លឹក (5) ។ បន្ទាប់មកបៀដែលចែកសល់ដាក់ក្នុងហ៊ូនៅលើតុ សង់ចំនួនបីខ្ទង់តួលេខដោយដាក់ផ្ងារបីសន្លឹកបៀខាងលើនៅជិតៗគ្នា ហើយអ្នកចែករៀបសន្លឹកបៀតាមលំដាប់។ បន្ទាប់ មកអ្នកចែកបៀទល់មុខពិនិត្យពិច័យបៀរបស់គេ។ ប្រសិនបើសន្លឹកបៀមួយសន្លឹកដែលគេកាន់នោះមានចំនួនតួលេខអាចចែកដាច់ (គ្មានសំណល់)គេអាចចាប់យកទាំងបួនសន្លឹក (សន្លឹកបៀដែលមានចំនួនបីខ្ទង់តួលេខ និងខ្លួនឯងមួយសន្លឹកដែលកំពុងលេង)។ ចំនួន បីខ្ទង់តួលេខថ្មីត្រូវបានសង់ ហើយអ្នកចែកបៀប៉ុនប៉ងលេងបៀដែលកាន់នៅនឹងដៃឲ្យចែកដាច់នឹងចំនួន បីខ្ទង់តួលេខថ្មីនេះ។

ប្រសិនបើអ្នកលេងមានសន្លឹកបៀនៅនឹងដៃដែលពុំអាចចែកដាច់នឹងចំនួនបីខ្ទង់តួលេខ នោះអ្នកលេងបន្តទៅឲ្យគូរបដិបក្សរបស់គេដែលគេមានឱកាសនឹងចាប់យកសន្លឹកបៀដែលអាចចែកដាច់នឹងចំនួននោះ។ ប្រសិនបើគ្មានអ្នកណាម្នាក់មានសន្លឹកបៀមិនអាចចែកដាច់នឹងចំនួនបីខ្ទង់តួលេខសោះនោះ អ្នកលេងត្រូវរៀបចំសន្លឹកបៀម្តងទៀតដើម្បីឲ្យអាចចែកដាច់នឹងចំនួនបីខ្ទង់តួលេខនោះ។ ប្រសិនបើនៅតែពុំអាចធ្វើបានទៀតនោះ ត្រូវប្រមូលបៀចូលហ៊ូវិញ គូរបៀបីសន្លឹកថ្មី ហើយសង់ចំនួនបីខ្ទង់តួលេខថ្មី។

ប្រសិនបើអ្នកលេងម្នាក់ លេងបៀដែលគេគិតថាអាចចែកនឹងចំនួនខ្ទង់តួលេខច្រើន ប៉ុន្តែមិនអាចធ្វើបាន នោះអ្នកលេងដែលជាគូរបដិបក្សអាចដណ្តើមយក។ ប្រសិនបើការដណ្តើមយកនេះគិតថាត្រឹមត្រូវ (ដោយវិធីចែក) នោះអ្នកលេងដែលយល់ច្រឡំចាញ់សន្លឹកបៀទៅនឹងគូរបដិបក្សដណ្តើមយក។ ពុំមាន ការដាក់ពិន័យសំរាប់ការដណ្តើមយកខុសនោះទេ។ បន្ទាប់មកគូរបដិបក្សមានឱកាសលេងបៀដែលអាចចែក ដាច់នឹងចំនួនច្រើនខ្ទង់តួលេខ ហើយចាប់យកសន្លឹកបៀនោះ។

ការលេងធ្វើបន្ត រហូតដល់មិនអាចសង់ចំនួនបីខ្ទង់តួលេខបាន ឬការលេងមិនអាចធ្វើបាន (វាជាការចាំបាច់ដែលត្រូវសាប់បៀដែល នៅសល់ក្នុងហ៊ូម្តងទៀត ដើម្បីបង្កើតការបញ្ចូលគ្នានូវចំនួនបីខ្ទង់តួលេខថ្មីខ្លះដែល អាចចែកដាច់)។ យកចេញសន្លឹកបៀណាដែលមិនអាចប្រើការបាន(នៅក្នុងដៃអ្នកលេង និង/ឬក្នុងហ៊ូ)ហើយ រាប់សន្លឹកបៀដែលចាប់យក។ អ្នកលេងដែលចាប់យកសន្លឹកបៀច្រើនជាងគេបង្អស់នោះឈ្នះជុំលេងនេះ។

**សារៈសំខាន់ :** នៅពេលចាប់យកសន្លឹកបៀ អ្នកលេងគួរតែប្រាប់ដំណឹងពីក្បួនចែកដាច់ ដែលបានលើក ឡើងថា ចំនួនបីខ្ទង់តួលេខគឺអាចចែកដាច់ នៅសន្លឹកបៀដែលលេងនេះឬបង្ហាញការចែកលេខជាក់ស្តែងនៅ លើក្រដាសដោយប្រើខ្មៅដៃ។
ប្រើម៉ាស៊ីនគិតលេខ បើមានលទ្ធភាព ដើម្បីគាំទ្រការដណ្តើមយកឲ្យបាន និងផ្ទៀងផ្ទាត់ការគណនានៅលើក្រដាសដោយខ្មៅដៃ។

**ឧទាហរណ៍ទី 1:** ចំនួនបីខ្ទង់តួលេខត្រូវបានសង់ 315។ អ្នកលេង A ចាប់យកបានសន្លឹកបៀលេខ 5 ពីព្រោះ តួលេខខាងចុង 5 អាចចែកដាច់នឹង 5។ អ្នកលេងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការលេងដោយចែក 315 និង 5 ហើយរកលទ្ធផលឃើញ 63 ដោយគ្មានសំណល់។ ចំនួនបីខ្ទង់តួលេខថ្មីត្រូវបានសង់សំរាប់ វេនអ្នកលេង B។

**ឧទាហរណ៍ទី 2:** ចំនួនបីខ្ទង់តួលេខគឺ 333។ អ្នកលេង B ប៉ុនប៉ងចាប់យកសន្លឹកបៀលេខ 6។ អ្នកលេង A ព្យាយាមប្រឹងប្រែង ហើយធ្វើចំណោទចែកលេខយ៉ាងវែង $333 \div 6$ ដោយរកផលចែកនោះគឺ 55 r 3 (ឬ 55.5 នៅលើម៉ាស៊ីនគិតលេខ)។ 6 មិនអាចចែកដាច់នឹងលេខ 333 អ្នកលេង B ចាញ់ការលេងចំពោះសន្លឹក បៀរបស់គេ។ បន្ទាប់មកអ្នកលេង A ចាប់យកចំនួនបីខ្ទង់តួលេខ 333 ចែកនឹង 9 នៃសន្លឹកបៀរបស់គេ ពីព្រោះ 333 ចែកនឹង 9 ស្មើនឹង 37 (គ្មានសំណល់)។

## ក្បួនចែក

| | | |
|---|---|---|
| សូន្យ | **0** | មេចែកសូន្យមិនអាចចែកបាន |
| មួយ | **1** | គ្រប់លេខទាំងអស់ចែកដាច់នឹងមួយ |
| ពីរ | **2** | កាលណាតួលេខខាងចុងនៃចំនួននោះស្មើនឹង 0 2 4 6 ឬ 8។ |
| បី | **3** | ប្រសិនបើផលបូកតួលេខនៃចំនួននោះចែកដាច់នឹងបី។ឧទា. 117... បូកតួលេខ 1 +1 +7= 9 9 គឺអាចចែកដាច់នឹង 3 ហេតុដូច្នេះ (ផលចែក=39)។ |
| បួន | **4** | ប្រសិនបើចំនួនពីរតួលេខខាងចុងជាលេខ 00 ឬចំនួនពីរតួលេខខាងចុងនៃចំនួននោះចែកដាច់នឹង 4។ ឧទា. 536... តួលេខពីរខាងចុង 36 គឺជាអាចចែក ដាច់នឹង 4 ហេតុដូច្នេះ (ផលចែក 134)។ |
| ប្រាំ | **5** | កាលណាតួលេខខាងចុងនៃចំនួននោះស្មើនឹង 0 ឬ 5។ |
| ប្រាំមួយ | **6** | កាលណាតួលេខជាចំនួនគូ (ចែកដាច់នឹង 2) ដែលផលបូកតួលេខនៃចំនួននោះចែកដាច់នឹង 3។ ឧទា. 180... ជាលេខគូ ពីព្រោះតួលេខខាងចុងជាលេខ 0 ហើយដែល 1 + 8 + 0 = 9 អាចចែកដាច់នឹង 3 ដូច្នេះ 180 (ផលចែក = 30)។ |

| | | |
|---|---|---|
| ប្រាំពីរ | 7 | គុណតួលេខខាងចុងនឹងពីរ ហើយយកលទ្ធផលដែលបានពីគុណនោះ ទៅដកជាមួយចំនួនតួលេខនៅសល់ខាងដើម។ប្រសិនបើលទ្ធផលដែលបាន ពីការដកលេខ អាចចែកដាច់នឹង 7 នោះតួលេខអាចចែកដាច់ ។ ឧទា. 364…4 x 2 = 8 36 – 8 = 28 ដែលអាចចែកដាច់នឹង (28 ÷7 = 4) ដូច្នេះ 364 (ផលចែក = 52)។ |
| ប្រាំបី | **8** | ប្រសិនបើចំនួនបីតួលេខខាងចុងជាលេខ 000 ឬចំនួនបីតួលេខខាងចុង នៃចំនួននោះចែកដាច់នឹង8 ។ឧទា. 5,120… ចំនួនតួលេខបីខាងចុង 120 អាចចែកដាច់នឹង 8។ (ផលចែក 15)ដូច្នេះ 5,120 (ផលចែក=640)។ |
| ប្រាំបួន | **9** | ប្រសិនបើផលបូកតួលេខនៃចំនួននោះអាចចែកដាច់នឹង 9។ ឧទា. 378... បូក តួលេខ 3 + 7 + 8 = 18 18 គឺអាចចែកដាច់នឹង 9 ហេតុដូច្នេះ 378 (ផលចែក = 42)។ |
| ដប់ | **10** | កាលណាតួលេខខាងចុងនៃចំនួននោះស្មើនឹងសូន្យ (0) អាចចែកដាច់ នឹង 10។ |

### ស្តង់ដាថ្នាក់ទីបួន៖ ចំនួន 1.6

សិស្សសរសេរសញ្ញាណប្រភាគ និងចំនួនទសភាគជាខ្ទង់ភាគដប់ ខ្ទង់ភាគរយ និងស្គាល់សមមូលប្រភាគ និងចំនួន ទសភាគ សំរាប់សរសេរចំនួនទសភាគជាប្រភាគ និងចំនួនចំរុះ។

## ស្តង់ដាថ្នាក់ទីប្រាំ៖ ចំនួនស្រដៀង 1.2

សិស្សរកសមមូលនៃចំនួនទសភាគ និងភាគរយជាប្រភាគរួម និងពន្យល់ពីមូលហេតុអ្វី បានជាវាមានតម្លៃដូចគ្នា។

# *ការផ្គូរផ្គងសមមូល*

## សម្ភារៈបង្រៀន៖ បញ្ជីរាយចំនួន ប្រអប់ទទេ ជ័រកាវ និងស្កុត

វត្ថុនៃល្បែងនេះគឺផ្គូរផ្គងប្រភាគទៅនឹងសមមូលនៃចំនួនទសភាគ។ នៅសន្លឹកបន្ទាប់នៃសៀវភៅនេះមានបញ្ជីរាយប្រភាគ។ កាត់ជុំវិញលេខ។ បិទជ័រកាវឬបិទស្កុតនៃបញ្ជីប្រភាគ នេះនៅលើផ្ទៃប្រអប់ទទេ។ នៅពេលជ័រកាវស្ងួត ផ្កាប់ប្រអប់មកវិញដោយហើយធ្វើយ៉ាងណាអោយ អ្នកអាចមើលឃើញរូបភាពនេះ។ រូបភាព និងលេខត្រូវនៅម្ខាងម្នាក់នៃប្រអប់។

ត្រឡប់ប្រអប់ឲ្យឃើញលេខ ហើយកាត់លេខទាំងនោះតាមគែមរបស់វារាងជាខ្សែ។

ដើម្បីលេងល្បែងផ្គូរផ្គងសមមូលត្រូវ៖

1- ផ្កាប់លេខទាំងនោះកុំឲ្យឃើញ (អ្នកអាចមើលឃើញរូបភាព ប៉ុន្តែមិនអាចមើលឃើញលេខទេ)។

2- ច្របល់លេខទាំងនោះ។

3- ដាក់ប្រភាគតូចជាងគេនៅខាងលើ ឆ្វេងនៃផ្ទៃលេងរបស់អ្នក។

4- ដាក់សមមូលចំនួនទសភាគឲ្យចំខាងស្តាំនៃប្រភាគ ដើម្បីធ្វើការផ្គូរផ្គងសមមូល។

5- បន្ទាប់មកដាក់ប្រភាគតូចជាងនៅខាងស្តាំនៃការផ្គូរផ្គងសមមូលមុន។

6- ដាក់សមមូលចំនួនទសភាគឲ្យចំខាងស្តាំនៃប្រភាគដើម្បីធ្វើការផ្គូរផ្គងសមមូលផ្សេងទៀត។

7- បន្ទាប់មកទៀតដាក់ប្រភាគតូចជាង និងការផ្គូរផ្គងសមមូលទសភាគនៅពីក្រោមការផ្គូរផ្គងលើក ទីមួយ។

8- ដាក់សមមូលប្រភាគតូចជាងនិងការផ្គូរផ្គងសមមូលចំនួនទសភាគឲ្យចំខាងស្តាំនៃការផ្គូរផ្គងសមមូលដូចជំហានទី៧។

9- បន្តសកម្មភាពនេះរហូតដល់អ្នកធ្វើបានត្រឹមត្រូវនៃការផ្គូរផ្គងសមមូលទាំងប្រាំបី។

10- ពិនិត្យមើលថាអ្នកបានរៀបតាមលំដាប់និងការផ្គូរផ្គងសមមូលនេះបានត្រឹមត្រូវ ដោយផ្កាប់លេខនីមួយៗចុះក្រោម។

11- ប្រសិនបើអ្នកធ្វើបានត្រឹមត្រូវ រូបភាពប្រអប់ត្រូវលេចឡើងបានត្រឹមត្រូវ ដូចអ្នកបាន កាត់រូបភាពលើកមុន។

### ឧទាហរណ៍៖

**ម្ខាងលេខ**

| | | | |
|---|---|---|---|
| $\frac{1}{4}$ | 0.25 | $\frac{1}{2}$ | 0.5 |
| $\frac{3}{4}$ | 0.75 | $1\frac{1}{4}$ | 1.25 |
| $1\frac{1}{2}$ | 1.5 | $1\frac{3}{4}$ | 1.75 |
| $2\frac{1}{4}$ | 2.25 | $2\frac{1}{2}$ | 2.5 |

**ម្ខាងរូបភាព**



**ស្តង់ដាថ្នាក់ទីបួន ៖ ចំនួន** 1.9

សិស្សកំណត់រកទីតាំងរ៉ឺឡាទីបនៃប្រភាគវិជ្ជមាននៅលើបន្ទាត់ចំនួន។

**ស្តង់ដាថ្នាក់ទីប្រាំ ៖ ចំនួន 1.5**

សិស្សកំណត់រក និងតាងប្រភាគនៅលើបន្ទាត់ចំនួន។

# សកម្មភាពប្រភាគ

## សង់ និងប្រៀបធៀបប្រភាគនៅលើបន្ទាត់ចំនួន។

**សម្ភារៈបង្រៀន ៖** តុស្តង់ដាលេងបៀចំនួនប្រភាគបន្ទាត់ ចម្រៀកទ្រនង់ បន្ទាត់ ខ្សែ ភេននី ឌីម ឬហ្វីតតូចៗ។

វត្ថុនៃសកម្មភាពនេះ គឺសង់ប្រភាគសមស្របធំបំផុត និងកំណត់រកតម្លៃរ៉ឺឡាទីបរបស់វា ទៅនឹងចំនួនប្រភាគបន្ទាត់ ផ្សេងទៀត។

នៅទំព័របន្ទាប់ គឺជាចំនួនប្រភាគបន្ទាត់។ អ្នកបិទការឬស្កុតនៃបន្ទាត់ចំនួននៅលើផ្ទៃប្រអប់ទទេឬ ក្រដាសរឹងដើម្បី ឲ្យរឹងមាំ។ អ្នកលេងម្នាក់ៗដៅហ្វីតរបស់គេរៀងៗខ្លួននៅខាងលើនៃក្ងឡោន (លេខ 1)។ អ្នកលេងពីពីរនាក់ទៅដប់នាក់។ ដកសន្លឹកបៀរូប ស្តេចប្រុស ស្តេចស្រី កំឡោះចេញពីតុលេង ដោយទុកតែសែសិបសន្លឹកបៀប៉ុណ្ណោះ។ បៀរូបអាត់តាងលេខមួយ (1) និងសន្លឹកបៀផ្សេងៗទៀតគឺស្មើនឹងតម្លៃលេខនៅក្នុងបៀរបស់វា។

សាប់បៀទាំងអស់នោះ ហើយចែកឲ្យអ្នកលេងម្នាក់ៗពីរសន្លឹក។ បន្ទាប់មកអ្នកលេងរៀបសន្លឹកបៀដាក់លើគ្នាដើម្បីបង្កើតប្រភាគ។ សន្លឹកបៀលេខតូចជាងត្រូវនៅខាងលើ(ភាគយក) និងសន្លឹកបៀលេខធំជាងត្រូវនៅខាងក្រោម (ភាគបែង)។ ប្រសិនបើសន្លឹកបៀទាំងពីរមានតម្លៃលេខស្មើគ្នា នោះភាគយក និងភាគបែងស្មើគ្នា ហើយសមមូល ប្រភាគស្មើនឹងមួយ (1) ត្រូវបានបង្កើត។ បន្ទាប់មកនៅពេលអ្នកលេងម្នាក់ៗសង់ប្រភាគរបស់គេ អ្នកលេងដៅ ហ្វីតស្របនឹងប្រភាគនៅលើបន្ទាត់ចំនួនប្រភាគ។ អ្នកលេងណាដែលដៅហ្វីតទៅខាងស្តាំលឿនជាងគេបំផុត មាន ប្រភាគធំបំផុត នោះឈ្នះការលេងនេះ។ អ្នកដែលមានសន្លឹកបៀច្រើនជាងគេគឺអ្នកឈ្នះ។

អ្នកអាចប្រើចម្រៀកទ្រនង់ បន្ទាត់ ឬខ្សែ ដើម្បីផ្ទៀងផ្ទាត់ថាតើប្រភាគណាស្មើគ្នាឬធំបំផុត ដោយដាក់ចម្រៀកទ្រនង់ទៅខាងស្តាំបន្ទាប់ក្បែរគែមនៃការប្រភាគ។ ប្រសិនបើចំនួនស្មើគ្នា សន្លឹកបៀទាំងអស់ត្រូវមូលជុំវិញ ហើយការលេង ធ្វើបន្តទៀត។

**ឧទាហរណ៍ ៖** អ្នកលេងបួននាក់សង់ប្រភាគបន្តបន្ទាប់ជាមួយនឹងសន្លឹកបៀរបស់គាត់ ហើយដៅហ្វីតពីក្រោម បន្ទាត់ចំនួន។

| | | | |
|---|---|---|---|
| 3 | 1 | 2 | 1 |
| 4 | 2 | 3 | 4 |




ដៅហ្វីតដាក់ $\frac{3}{4}$ គឺឆ្ងាយបំផុតទៅខាងស្តាំ ហេតុដូច្នេះអ្នកលេងមានប្រភាគធំបំផុតឈ្នះជុំលេងនេះ និងប្រមូលបៀ ទាំង៨សន្លឹក។

**បំរែបំរួល:** សាកល្បងធ្វើប្រភាគតូចបំផុត និង /ឬសាកល្បងធ្វើប្រភាគជិតបំផុតមួយភាគពីរ។

# បន្ទាត់ចំនួនប្រភាគ

**1**

$\frac{1}{2}$ | $\frac{2}{2}$

$\frac{1}{3}$ | $\frac{2}{3}$ | $\frac{3}{3}$

$\frac{1}{4}$ | $\frac{2}{4}$ | $\frac{3}{4}$ | $\frac{4}{4}$

$\frac{1}{5}$ | $\frac{2}{5}$ | $\frac{3}{5}$ | $\frac{4}{5}$ | $\frac{5}{5}$

$\frac{1}{6}$ | $\frac{2}{6}$ | $\frac{3}{6}$ | $\frac{4}{6}$ | $\frac{5}{6}$ | $\frac{6}{6}$

$\frac{1}{7}$ | $\frac{2}{7}$ | $\frac{3}{7}$ | $\frac{4}{7}$ | $\frac{5}{7}$ | $\frac{6}{7}$ | $\frac{7}{7}$

$\frac{1}{8}$ | $\frac{2}{8}$ | $\frac{3}{8}$ | $\frac{4}{8}$ | $\frac{5}{8}$ | $\frac{6}{8}$ | $\frac{7}{8}$ | $\frac{8}{8}$

$\frac{1}{9}$ | $\frac{2}{9}$ | $\frac{3}{9}$ | $\frac{4}{9}$ | $\frac{5}{9}$ | $\frac{6}{9}$ | $\frac{7}{9}$ | $\frac{8}{9}$ | $\frac{9}{9}$

$\frac{1}{10}$ | $\frac{2}{10}$ | $\frac{3}{10}$ | $\frac{4}{10}$ | $\frac{5}{10}$ | $\frac{6}{10}$ | $\frac{7}{10}$ | $\frac{8}{10}$ | $\frac{9}{10}$ | $\frac{10}{10}$

**ស្តង់ដាថ្នាក់ទីបួនៈ ចំនួន 2.2**

សិស្សបង្គត់ចំនួនទសភាគ២ខ្ទង់ឲ្យទៅជាទសភាគ១ខ្ទង់ ឬបង្គត់ចំនួនគត់ជិតបំផុត និងវិនិច្ឆ័យភាព ចម្លើយបង្គត់ចំនួន។

**ស្តង់ដាថ្នាក់ទីប្រាំៈ ចំនួន ១។១**

សិស្សប៉ាន់ស្មាន បង្គត់ និងសំរបសំរួលចំនួនធំបំផុត និងចំនួនតូចបំផុត។

# ការទៅផ្សារទំនើប

ជូម៉ូនិចបានទៅផ្សារទំនើប TRC។ នាងត្រូវការឲ្យអ្នកជួយបង្គត់តម្លៃទំនិញនីមួយៗនៃចំនួនគត់ជិតបំផុត ជាដុល្លា និងបូកសរុប បង្គត់តម្លៃទំនិញទាំងអស់ដើម្បីចង់ដឹងថាតើតម្លៃសរុបនៅលើវិក័យប័ត្រសមហេតុផល ដែរឬទេ។

ចម្លងបញ្ជីតម្លៃនៅជួរខាងស្តាំដៃនៃវិក័យប័ត្រនេះលើក្រដាសដាច់ដោយឡែក។ នៅក្បែរតម្លៃទាំងនោះ សរសេរបង្គត់ប៉ាន់ស្មាន តម្លៃទៅនឹងចំនួនគត់ជិតបំផុតជាដុល្លា។ ប្រសិនបើអ្នកប៉ាន់ស្មានតម្លៃសមហេតុផល បន្ទើនឹងសមតុល្យ។ បន្ទាប់មកប៉ាន់ស្មាន តម្លៃពន្ធ និងបូកបញ្ចូលវាទៅនឹងការប៉ាន់ស្មានតម្លៃរបស់អ្នក ដើម្បីឲ្យឃើញថាតើតម្លៃសរុបរបស់ជូម៉ូនិចសមហេតុផលដែរឬទេ។

ផ្សារទំនើប TRC -1234 Profit Road, Long Beach, CA

អ្នកពិនិត្យមើលការយកទំនិញចេញ គឺម៉ាយូ

| | |
|---|---|
| ការ៉េមវ៉ានីឡាឡៃតឹ៍ 1ក្វាត | 1.59 |
| ចេក 1 lb. | 1.99 |
| នំប៉័ងម្សៅសាឡីទាំងមូល | 2.49 |
| ត្រពាំងបារាំង 1 lb. | 3.19 |
| ស្លឹកសាឡាត់ | 0.79 |
| ទឹកប៉េងប៉ោះ 1ក្វាត | 2.19 |
| 1% ទឹកដោះគោ 1កាឡុង(Gallon) | 3.59 |
| ចំណីឆ្មា 3@ .33 | 0.99 |
| នុយ និងប្រូម៉ា | 029 |
| នំសុកកូឡា | 2.15 |
| ម្សៅសាប៊ូបោកខោអាវ | 4.65 |
| ស៊ុត 1ឡូ | 1.89 |
| ទឹកសុទ្ធ 1លីត 2.49 | 1.39 |
| អំពូលភ្លើង 60 Watt 4 កញ្ចប់ | 3.27 |
| បើរមិនធាត់ | 2.15 |
| អង្គរ 1 lb. | 1.78 |
| ផ្លែឈើគីច 2 lb. @ .69 ក្នុង1b | 1.38 |
| មាន់ទាំងមូល 3 lb @ 1.19ក្នុង 1lb | 3.57 |
| ត្រីសូម៉ុងពិសេស 1 lb @ 5.69ក្នុង 1lb | 5.69 |
| សមតុល្យ | 45.03 |
| ****ថ្លៃពន្ធ | 3.60 |
| សរុប | 48.63 |
| បេឡា | 50.00 |
| អាប់ប្រាក់ | 1.37 |

សរុបចំនួនមុខទំនិញដែលលក់ =20

អរគុណអញ្ជើញមកផ្សារទំនើប TRC

**កំណត់ចំណាំៈ** សមតុល្យប៉ាន់ស្មានគឺ :2 + 2 + 2 + 3 + 1 + 2 + 4 + 1 + 0 + 2 + 5 + 2 + 1 + 3 + 2 + 2 + 1 + 4+ 6 = $45, ដែលតម្លៃនេះសមហេតុផល ខិតជិតនឹងសមតុល្យជាក់ស្តែង $45.03។ ការប៉ាន់ស្មានថ្លៃពន្ធគឺ$4 ដែលនៅពេលបូកសរុបនោះ សមតុល្យប៉ាន់ស្មានមានតម្លៃសរុប $49 ដែលតម្លៃនេះសមហេតុផល គឺខិតជិតនឹងតម្លៃសរុបជាក់ស្តែង $48.63។

**ការពង្រីកទីមួយៈ** ឲ្យកូនអ្នកបង្គត់តម្លៃទំនិញជាប្រាក់ឌីមជិតបំផុត ($0.10)។ តើការបង្គត់តម្លៃនេះផ្តល់ការប៉ាន់ស្មានតម្លៃកាន់តែ ត្រឹមត្រូវដែរឬទេ?

**ការពង្រីកទីមួយៈ** ឲ្យកូនអ្នករក្សាទុកកូនក្រដាសប៉ាន់ស្មានតម្លៃជាប់នឹងខ្លួន សំរាប់លើកក្រោយពេលអ្នកទៅផ្សារនោះ អ្នកចង់ដឹងថា កូនអ្នកពិតជាអ្នកទោះទាយតម្លៃទំនិញសមហេតុផលទៅនឹងតម្លៃសរុបជាក់ស្តែង ឬបើមិនដូច្នោះទេ ត្រូវសន្សំទុកវិក័យ ប័ត្រគ្រឿងទេស និងឲ្យកូនអ្នកធ្វើសកម្មភាពប៉ាន់ស្មានតម្លៃទំនិញជាមួយវិក័យប័ត្រជាក់ស្តែង។

**ស្តង់ដាថ្នាក់ទីបួន ៖ ចំនួន 4.2**

សិស្សយល់ដឹងចំនួនដូចជា 2, 3, 5, 7 និង11 ពុំមានកត្តាច្រើនទេ លើកលែងតែលេខមួយ(1) និងខ្លួនឯង។ ចំនួនទាំងនោះហៅថាចំនួនបឋម។

**ស្តង់ដាថ្នាក់ទីប្រាំ៖ វិចារគណិតវិទ្យា 1.4**

សិស្សកំណត់រកកត្តាបឋមនៃចំនួន 50។

# ភស្តុតាងនៃអ៊ីរ៉ាតូស្ទែន (រ៉ោត ឲ្យសតហានេសេ)

**ការកំណត់រកចំនួនបឋម**



**សម្ភារ ៖** ខ្មៅដៃពណ៌ខ្មៅ ឬខ្មៅដៃពណ៌

ចំនួនបឋមជាចំនួនដែលមានកត្តាតែពីរគត់គឺលេខមួយ និងខ្លួនឯង។ ចំនួនដែលមានកត្តាលើសពីពីរកត្តា ហៅថាចំនួនមិនបឋម។ កត្តាគឺជាចំនួនពីរឬច្រើនដែលអាចគុណជាមួយគ្នា។

នៅក្នុងសតវត្សទី៣ មុនគ.សអ៊ីរ៉ាតូស្ទែនបានបង្កើតវិធីសាស្ត្រងាយបំផុតដើម្បីរកចំនួនបឋម។ ប្រសិនបើ យើងចង់រកចំនួនបឋមទាំងអស់រវាងលេខ ១ និងលេខ ៥០ យើងត្រូវសរសេរក្នុងតារាងនូវចំនួនទាំងនេះ។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ |
| ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ |
| ២១ | ២២ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ |
| ៣១ | ៣២ | ៣៣ | ៣៤ | ៣៥ | ៣៦ | ៣៧ | ៣៨ | ៣៩ | ៤០ |
| ៤១ | ៤២ | ៤៣ | ៤៤ | ៤៥ | ៤៦ | ៤៧ | ៤៨ | ៤៩ | ៥០ |

ប្រើខ្មៅដៃពណ៌ខ្មៅ ឬខ្មៅដៃពណ៌ដើម្បីគូរត្រីកោណជុំវិញលេខមួយ (1)។ លេខមួយមិនមែនជាចំនួនបឋម ហើយក៏មិនមែនជាចំនួនមិនបឋមដែរ ពីព្រោះវាមានតែមួយកត្តាប៉ុណ្ណោះ គឺលេខមួយ (1)។

គូររង្វង់ពណ៌ក្រហមជុំវិញលេខពីរ។ ឥឡូវនេះគូសខ្វែងលេខទាំងអស់ដែលគុណនឹងពីរ(4, 6, 8...)។ លេខបន្ទាប់ដែលមិនគូសខ្វែងគឺលេខបី។ គូររង្វង់ពណ៌ខៀវជុំវិញលេខបី ហើយគូសខ្វែងលេខដែល គុណជាមួយវា។ លេខបន្ទាប់ដែលមិនគូសខ្វែងគឺលេខ 5គូររង្វង់ពណ៌បៃតងជុំវិញវា ហើយគូសខ្វែង លេខដែលគុណជាមួយវា។ ធ្វើបន្តនីតិវិធីនេះរហូតដល់លេខទាំងអស់ធំជាងមួយដែលបានគូររង្វង់ (ជាចំនួនបឋម) ឬគូសខ្វែង (ជាចំនួនមិនបឋម)។

**កំណត់ចំណាំ ៖** ចំនួនបឋមរវាងលេខមួយ និងលេខហាសិបដែលបានគូររង្វង់គឺ ៖ 2, 3, 5, 7, 11, 13, 17, 19, 23, 29, 31, 37, 41, 43, & 47.

**ស្តង់ដាថ្នាក់ទីបួន : លេខ 1.8**

សិស្សប្រើគោលគណិតនៃលេខអវិជ្ជមាន(ឧ.នៅលើផ្លូវបន្ទាត់លេខ)

**ស្តង់ដាថ្នាក់ទីប្រាំ: លេខ 1.5**

សិស្សរកមើលហើយគូសលេខលើផ្លូវបន្ទាត់លេខវិជ្ជមាននិងអវិជ្ជមាន។

# លេខស្ទីតដប់ប្រាំមួយ

## ល្បែងនៃចំនួនវិជ្ជមាន និងអវិជ្ជមាន

**សម្ភារៈ** តុលេងបៀ ប្រអប់ទទេ ស្កុត ឬជ័រការ ក្តារល្បែងបន្ទាត់លេខវិជ្ជមាននិងអវិជ្ជមាន កាក់១សេន កាក់១០សេន។

- នេះគឺជាល្បែងសំរាប់អ្នកលេងពីរនាក់។ វត្ថុនៃល្បែងនេះគឺអ្នកលេងទីមួយដាក់កាក់នៅលើលេខ 16 ឬ -16។

នៅទំព័របន្ទាប់នៃកូនសៀវភៅនេះគឺជាក្តារល្បែងបន្ទាត់លេខស្ទីតវិជ្ជមាន និងអវិជ្ជមាន។ កាត់ជុំវិញបន្ទាត់ លេខជាបីចំណែក ហើយបិទនៅលើប្រអប់ទទេ(ឬក្រដាសកាតុងរឹង)នឹងជ័រការ។ បន្ទាប់មកកាត់បន្ទាត់លេខ វាចេញ ហើយដាក់វានៅលើតារាងខាងលើជាមួយគ្នា។ មួយចំណែកដែលមានលេខពី □១៦ ទៅ □៦ ត្រូវដាក់ នៅខាងឆ្វេង។

មួយចំណែកទៀតដែលមានលេខពី □៥ដល់ ៥ ត្រូវដាក់នៅចំកណ្តាល រួចតំរៀប ផ្លូវអង្កត់បន្ទាត់លេខ ដូច្នេះយើងឃើញលេខ □៦ ានជ □៥ នឹងនៅជាប់គ្នា។ ចំណែក ទីបីដែលមានលេខពី ៦ ដល់ ១៦ ត្រូវដាក់នៅខាងស្តាំ ដូច្នេះយើងឃើញលេខ ៥ និង ៦ នៅជាប់គ្នា។ (អ្នកបិទស្កុតលើអង្កត់បន្ទាត់ លេខទាំងបីជាមួយគ្នាដើម្បីអោយបន្ទាត់លេខរឹងមាំ)។

ឧទាហរណ៍ចំណែកមួយនៃក្តារល្បែងបន្ទាត់លេខ:

| | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| -៩ | -៨ | -៧ | -៦ | -៥ | -៤ | -៣ | -២ | -១ | ០ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ |

តាមស្តង់ដា52សន្លឹកបៀ ដកសន្លឹកបៀរូបកញ្ចាស់ ក្រមុំ កំឡោះ និងដប់ចេញ ទុកតែសាមសិបប្រាំមួយ សន្លឹកបៀប៉ុណ្ណោះ ដែលមានតម្លៃលេខលើសន្លឹកបៀពីមួយ (សន្លឹកអាត់)ដល់ប្រាំបួន។ សាប់បៀ ហើយ ផ្កាប់មុខចុះនៅពីមុខអ្នកលេង។.
អ្នកលេងទាំងពីរនាក់ដាក់កាក់ចំណាំនៅលើលេខសូន្យ (0)។
អ្នកលេងម្នាក់ៗឆ្លាស់គ្នាដោយហូតបៀមួយសន្លឹកហើយផ្ងារ។ សន្លឹកបៀពណ៌ខ្មៅ(ជ្លូងនិងប៊ិច) តាងលេខវិជ្ជមាន ហើយអ្នកលេងរំកិលហ្វីតទៅលេខខាងស្តាំដែលមានតម្លៃលេខលើសន្លឹកបៀនោះស្រាប់។ សន្លឹក បៀពណ៌ក្រហម (ការ៉ូនិងកឺ) តាងលេខអវិជ្ជមាន ហើយអ្នកលេងរំកិលហ្វីតទៅលេខខាងឆ្វេងដែលមាន តម្លៃលេខលើសន្លឹកបៀនោះស្រាប់។
អ្នកលេងទីមួយដាក់លើលេខ 16 ឬ –16 ឈ្នះល្បែងនេះ។ អ្នកលេងមិនអាចដាក់ហួសពីលេខ 16 ហើយប្រសិនបើគេបើកបៀដោយបង្ខំ នោះគេនឹងចាញ់បាត់បង់វេនរបស់គេ។ អ្នកដៃគូបើកសន្លឹកបៀ បន្តការលេង។ អ្នកលេងទាំងពីរអាចចាប់ចំលេខដូចគ្នា ប្រសិនបើមានការលេងបញ្ឈារ។ ឧទាហរណ៍ល្បែង:
អ្នកលេងដែលមានកាក់១សេនជាសំគាល់ បើកសន្លឹកបៀ3ប៊ិច ហើយដាក់កាក់របស់គាត់ក្នុងចន្លោះទីបីខាងស្តាំ (ដាក់លើចន្លោះលេខ3)។ អ្នកលេងដែលមានកាក់១០សេនបើកសន្លឹកបៀ10ការ៉ូ ហើយដាក់កាក់១០សេន របស់គាត់ក្នុងចន្លោះទីដប់ (ដាក់ក្នុងចន្លោះលេខ –10)។ អ្នកលេងដែលមានកាក់១សេនបើកសន្លឹកបៀ 5កឺ ហើយដាក់កាក់១សេនរបស់គាត់ខាងឆ្វេងនៅចន្លោះ –2 ពីព្រោះ $3 + (-5) = -2$។ អ្នកលេងដែលមានកាក់១០សេនបើកសន្លឹកបៀ 6កឺ ហើយដាក់ចន្លោះលេខ –16 បានឈ្នះល្បែងនេះ ពីព្រោះ $-10 + (-6) = -16$ ។

បំរែបំរួលៈ កាក់ភេននីចាប់ផ្តើមពីលេខ–16 ហើយកាក់ឌីមចាប់ផ្តើមលេខ16។ វត្ថុនៃល្បែងនេះ គឺអ្នកលេងទី១គូសហ្វីតចំណាំនៅក្នុងចន្លោះលេខសូន្យ។ បំរែបំរួលនេះ ប្រសិនបើ អ្នកលេងម្នាក់បើកសន្លឹកបៀ ដែលជាមូលហេតុបន្ទាត់លេខរបស់គាត់ "ធ្លាក់ " (ដោយបង្កើតលេខធំជាង 16ឬតូចជាង–16) អ្នកលេង នោះចាញ់ល្បែង។

**កំណត់ចំណាំ:** ប័ណ្ណសន្ទស្សន៍ 3x5 អាចជំនួសបៀមួយហ្វូ។ មុននឹងអ្នកចាប់ផ្តើមលេង សរសេរលេខពី1 ដល់ 9 លើប័ណ្ណពីរ។

**Sweet Sixteen**

# ផ្ទាំងល្បែងបន្ទាត់លេខច្រើនជាងសូន្យនិងតិចជាងសូន្យ

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| **-16** | **-15** | **-14** | **-13** | **-12** | **-11** | **-10** | **-9** | **-8** | **-7** | **-6** |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| **-5** | **-4** | **-3** | **-2** | **-1** | **0** | **1** | **2** | **3** | **4** | **5** |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| **6** | **7** | **8** | **9** | **10** | **11** | **12** | **13** | **14** | **15** | **16** |

**ស្តង់ដាថ្នាក់ទីបួន : ចំនួន 4.1**

សិស្សយល់ដឹងថាចំនួនគត់អាចបំបែកបានតាមវិធីផ្សេងៗ។

**ស្តង់ដាថ្នាក់ទីប្រាំ: វិចារគណិតវិទ្យា 2.0**

សិស្សប្រើយុទ្ធសាស្ត្រ បំណិន និងបញ្ញត្តិក្នុងការរកដំណោះស្រាយ។

# ល្បែងសាមសិបលេខ

**សម្ភារៈ** ល្បែងចតុរង្គ (ល្បែងអុក) ភេននី ឌីម ឬ ហ្វីត ក្តារល្បែងសាមសិបលេខ សន្លឹកក្រដាសពិន្ទុ។

វត្ថុនៃល្បែងនេះសំរាប់អ្នកលេងពីរនាក់ដណ្តើមយកពិន្ទុឲ្យបានខ្ពស់បំផុតដោយគ្របចំនួនគារ។

នៅលើទំព័របន្ទាប់នៃកូនសៀវភៅនេះគឺជាក្តារល្បែងសាមសិប។ អ្នកអាចកាត់ និងបិទវានៅលើជ្រុងប្រអប់ ទទេ (ឬក្រដាសកាតុង) ដើម្បីឲ្យវារឹង។

អ្នកលេងទីមួយប្រើក្រឡាចតុរង្គនឹងហ្វីតពណ៌ក្រហមរបស់គាត់ ហើយអ្នកដៃគូរបស់ទល់ប្រើហ្វីតពណ៌ខ្មៅ។ ភេននី និងឌីម (ឬប្រភេទហ្វីតពីរពណ៌ខុសគ្នាផ្សេងទៀត) អាចប្រើបានប្រសិនបើមិនមានក្រឡាចតុរង្គ។ ។

ក្រដាសដាច់ដោយឡែកធ្វើជាក្រដាសពិន្ទុដែលតាងប្រហាក់ប្រហែលនឹង :

| អ្នកលេង A | អ្នកលេង B |
|---|---|
| | |

អ្នកលេង A ចាប់ផ្តើមដាក់ហ្វីតរបស់គាត់លើលេខណាមួយនៅលើក្តារល្បែង ហើយកត់ត្រានៅលើសន្លឹកក្រដាសពិន្ទុ។ បន្ទាប់មកអ្នកលេង B ប្រើហ្វីតរបស់គាត់គ្របលេខកត្តាបឋមរបស់អ្នកលេង A ទាំងអស់នៅលើក្តារល្បែង។ គាត់បូកបន្ថែមលេខដែលគ្រប និងកត់ត្រាផលបូកនៅលើសន្លឹកក្រដាសពិន្ទុ។

ការលេងបន្តផ្លាស់ប្តូរបៀបនេះរហូតដល់ពុំមានលេខកត្តាបឋមគ្របដែលសេសសល់នៅលើក្តារល្បែង។ អ្នកលេងបូកសរុបពិន្ទុ ហើយអ្នកបានពិន្ទុខ្ពស់ឈ្នះ។

**ឧទាហរណ៍ :** អ្នកលេង A គ្របលេខ 27 ហើយកត់ត្រាពិន្ទុនៅលើសន្លឹកក្រដាសពិន្ទុ។ បន្ទាប់មក អ្នកលេង B គ្របលេខ 1, 3 និង 9 (ពីព្រោះ 1 x 27, និង 3 x 9 ជាលទ្ធផលនៃ 27)។ អ្នកលេង B បូកពិន្ទុរបស់គាត់ 1 + 3 + 9 = 13 ហើយកត់ត្រាទុកនៅលើសន្លឹកក្រដាសពិន្ទុ។

ដល់វេនរបស់គាត់ អ្នកលេង B សំរេចចិត្តគ្របលេខ 29 ប៉ុន្តែមិនអាចអនុញ្ញាតិធ្វើបានទេ ពីព្រោះកត្តាបឋមផ្សេងទៀតនៃ 29 គឺមានតែ 1 គត់ហើយ លេខនោះគឺបានគ្របរួចទៅហើយ។ អ្នកលេង B គ្របលេខ 30 ហើយកត់ត្រាលេខនោះនៅលើសន្លឹកក្រដាសពិន្ទុ។ បន្ទាប់មកអ្នកលេង A <u>គ្របលេខមិនកត្តា បឋមដែលនៅសល់</u>នៃ 30: 2, 5, 6, 10, និង 15 គាត់រកលទ្ធផលបូកសរុប 38 ហើយកត់ត្រាលេខនោះ នៅលើសន្លឹកក្រដាសពិន្ទុ។ ត្រូវកត់សំគាល់ថា អ្នកលេង A <u>មិនអាចបញ្ចូល</u> 1 ឬ 3 ទោះបីជាលេខទាំងពីរនេះជាកត្តាបឋមនៃ 30 ក៏ដោយ ពីព្រោះលេខទាំងនោះបានគ្របរួចហើយ។

នៅក្នុងដំណាក់កាលនេះ អ្នកលេង A បាននាំមុខគឺ 65 ទៅ 43 (27 + 38 > 13 + 30).

**បំរែបំរួលទីមួយ :** ប្រសិនបើអ្នកលេងគ្របលេខមិនត្រឹមត្រូវ (ពុំមានសេសសល់លេខកត្តាមិនគ្រប) អ្នកលេង B ប៉ុនប៉ងធ្វើដូចឧទាហរណ៍ខាងលើ នោះអ្នកដៃគូអាចដកហ្វីត ហើយអ្នកលេងនោះគ្មានពិន្ទុ និងបាត់បង់វេនរបស់ខ្លួន។

**បំរែបំរួលទីពីរ :** ប្រសិនបើអ្នកលេងធ្វេសប្រហែសដោយគ្របគ្រប់លេខកត្តាបឋមដែលមានស្រាប់ អ្នកដៃគូអាចទាមទារ (គ្រប) លេខទាំងនោះ បូកសរុបពិន្ទុ នៅលើសន្លឹកក្រដាសពិន្ទុ ហើយបន្ទាប់មក អាចឃាត់នៅទុកវេនជាប្រចាំរបស់គាត់។

**ស្តង់ដាថ្នាក់ទីបួន : ចំនួន 2.0**

សិស្សពង្រីកការយល់ដឹង និងប្រើវិធីបូក និងវិធីដកចំនួនទសភាគងាយៗនៃចំនួនគត់។

**ស្តង់ដាថ្នាក់ទីប្រាំ : ចំនួន 2.1**

សិស្សធ្វើវិធីបូក ដក គុណ និងចែកជាមួយចំនួនទសភាគ។

# ធ្វើរូបិប័ណ្ណ

## សម្ភារៈបង្រៀន : ប័ណ្ណរូបិប័ណ្ណជាចំនួនទសភាគ

កាត់ប័ណ្ណរូបិប័ណ្ណនៃចំនួនទសភាគចេញ ហើយបិទនៅលើប័ណ្ណសន្ទស្សន៍នៃផ្ទៃប្រអប់ទទេ ឬក្រដាសរឹង។ ប្រសិនបើអ្នកប្រើក្រដាសរឹង ឬផ្ទៃប្រអប់ទទេ ត្រូវកាត់ប័ណ្ណរូបិប័ណ្ណនៃចំនួនទសភាគនេះចេញ។

សកម្មភាពនៃវត្ថុនេះគឺអ្នកលេងទីមួយធ្វើរូបមួយដុល្លា ដោយបូកចំនួនដែលបានបង្ហាញនៅលើប័ណ្ណរូបិប័ណ្ណជាចំនួន ទសភាគ។

សាប់ប័ណ្ណហើយដាក់ផ្កាប់។ អ្នកលេងនីមួយៗគូរប័ណ្ណមួយក្នុងពេលតែមួយ។ អាចអ្នកលេងម្នាក់គូរប័ណ្ណ ដែលធ្វើឲ្យផលបូកលើសពីមួយដុល្លា អ្នកលេងនោះត្រូវយកប័ណ្ណចេញពីតុបោះចោលឬប័ណ្ណណាមួយនៃអ្នកផ្សេងទៀតដែលបានផ្ងារ។ អ្នកលេងដែលគូរប័ណ្ណតាមលំដាប់បន្តបន្ទាប់គ្នា អាចជ្រើសរើសយកប័ណ្ណផ្ងារនៅខាងលើ ឬគូរពីប័ណ្ណ ដែលផ្កាប់នៅលើតុ។

អ្នកលេងត្រូវកត់ត្រាទុក ផលបូកសមីការដែលបង្ហាញពីរបៀបពួកគេ "ធ្វើរូបិប័ណ្ណ"។

**បំរែបំរួលទីមួយ :** លេងធ្វើចំនួនដុល្លាផ្សេងៗទៀត : ពីរដុល្លា មួយដុល្លាកន្លះ ។ល។

**បំរែបំរួលទីពីរ :** " ចាយរូបិប័ណ្ណ" ចាប់ផ្តើមមួយដុល្លា ហើយដកចំនួននៅលើប័ណ្ណទសភាគរូបិប័ណ្ណ ដើម្បីឈានទៅលេខសូន្យគត់។ ប្រសិនបើអ្នកលេងម្នាក់គូរប័ណ្ណដែលមានលទ្ធផលតូចជាងសូន្យ នោះប័ណ្ណត្រូវតែបោះចោល ប្រើនីតិវិធីដូចគ្នាដូចបានបង្ហាញខាងលើ។.

# ក្តារល្បែងចំនួនសាមសិបលេខ

| | | | | |
|---|---|---|---|---|
| **1** | **2** | **3** | **4** | **5** |
| **6** | **7** | **8** | **9** | **10** |
| **11** | **12** | **13** | **14** | **15** |
| **16** | **17** | **18** | **19** | **20** |
| **21** | **22** | **23** | **24** | **25** |
| **26** | **27** | **28** | **29** | **30** |

## ថ្នាក់ទីបួន និងទីប្រាំៈ ព្រឹត្តិការណ៏នៃមូលដ្ឋានប្រមាណវិធីគុណ

# ល្បែងផលគុណ

**សម្ភារៈ** ហ្វីត (ពីរពណ៌ខុសៗគ្នា)

វត្ថុនៃល្បែងនេះគឺ គ្រប(ឬបិទ)បួនលេខក្នុងជួរៈ បញ្ឈរ ផ្ដេក ឬខ្វែង។

- អ្នកលេខទី១គូសហ្វីតចំណាំលើលេខក្នុងបញ្ជីកត្តាលេខ(លើក្ដារល្បែងខាងក្រោម)។ ក្នុងក្រឡាការ៉េដែលត្រូវបំពេញដោយហ្វីតពណ៌អ្នកលេងទី១នោះពុំមានចន្លោះទំនេរទេ ពីព្រោះមានកត្តាតែ១គត់ប៉ុណ្ណោះដែលត្រូវគូសចំណាំ វាអាចយកពីរកត្តាដើម្បីបង្កើតបានលទ្ធផលមួយ។ ពុំមានចន្លោះទំនេរសំរាប់បំពេញលទ្ធផលជាពណ៌នៃអ្នកលេងទីមួយទេ ពីព្រោះមានតែកត្តាតែមួយគត់ដែលបានកត់ចំណាំ វាអាចយកកត្តាពីរដើម្បីបានជាលទ្ធផល។
- អ្នកលេងទី2 គូសហ្វីតផ្សេងទៀតចំណាំនៅលើលេខណាមួយក្នុងបញ្ជីកត្តាលេខ (រួមទាំងលេខដូចគ្នា របស់អ្នកលេងទីមួយដែលបានគូសចំណាំ)។ ចន្លោះនៅលើក្ដារល្បែងមានផ្ទុកលទ្ធផលនៃពីរកត្តាដែល គូសពណ៌ចំណាំដោយអ្នកលេងទីពីរ។
- អ្នកលេងទីមួយយកហ្វីតគូសចំណាំលើលេខណាមួយនៃបញ្ជីកត្តាទៅលេខមួយផ្សេងទៀត ហើយលទ្ធផល ថ្មីត្រូវបានបំពេញពណ៌អ្នកលេងទីមួយ។
- ដល់វេនរបស់ខ្លួន អ្នកលេងម្នាក់ៗត្រូវប្រើពណ៌ហ្វីតឲ្យបានត្រឹមត្រូវ សំរាប់គូសចំណាំលទ្ធផលនៅ ក្នុងចន្លោះ។ ប្រសិនបើលទ្ធផលត្រូវបានដាក់ពណ៌រួចហើយ អ្នកលេងមិនត្រូវគូសចំណាំវេននោះទៀតទេ។ អ្នកឈ្នះគឺអ្នកលេងទីមួយដែលបានគូសចំណាំបួនចន្លោះក្នុងជួរ- បញ្ឈរ ផ្ដេក ឬខ្វែង។

### តារាងល្បែងផលគុណ

| | | | | | |
|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 |
| 7 | 8 | 9 | 10 | 12 | 14 |
| 15 | 16 | 18 | 20 | 21 | 24 |
| 25 | 27 | 28 | 30 | 32 | 35 |
| 36 | 40 | 42 | 45 | 48 | 49 |
| 54 | 56 | 63 | 64 | 72 | 81 |

បញ្ជីកត្តា

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 |

## លទ្ធផលល្បែង—ការបកស្រាយទី II

ល្បែងនេះលេងដូចគ្នានឹងលទ្ធផលល្បែង ប៉ុន្តែសង្កត់ធ្ងន់លើ "ហេតុការណ៍កាន់តែពិបាក" (កត្តា4—9)។

| | | | | |
|---|---|---|---|---|
| 16 | 20 | 24 | 25 | 28 |
| 30 | 32 | 35 | 36 | 40 |
| 42 | 45 | 48 | 49 | 54 |
| 56 | 63 | 64 | 72 | 81 |

## **Factor List** បញ្ជីកត្តា

| | | | | | |
|---|---|---|---|---|---|
| 4 | 5 | 6 | 7 | 8 | 9 |

**កំណត់ចំណាំ:** អ្នកអាចផ្តល់តារាងនៃប្រមាណវិធីគុណ ឬម៉ាស៊ីនគិតលេខដើម្បីឲ្យកូនអ្នកអាចផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃលទ្ធផលប្រមាណវិធីគុណដែលបានទោះទាយនៅពេលកំពុងលេងល្បែងនេះ។

នៅពេលកំពុងលេងល្បែង ឲ្យកូនអ្នកកត់ត្រាហេតុការណ៍នៃប្រមាណវិធីគុណលើសន្លឹកក្រដាសដោយឡែក។ សង្កេតឲ្យឃើញថាតើហេតុការណ៍ណាមួយដែលកូនអ្នកជួបការលំបាក សំរាប់លើកក្រោយជំរុញបន្ថែមទៀតដោយមានប័ណ្ណត្រីកោណឬប័ណ្ណចាំងភ្លឺ។

**ស្តង់ដាថ្នាក់ទីបួនៈ ពីជគណិត និងអនុគមន៍ 2.0**

សិស្សប្រើការ៉ូកូអរដោណេ ២ទំហំដើម្បីតាងចំណុច និងក្រាបខ្សែ និងរូបភាពងាយៗ។

**ស្តង់ដាថ្នាក់ទីប្រាំៈ ពីជគណិត និងអនុគមន៍ 1.4**

សិស្សកំណត់រក និងគូរក្រាបលំដាប់គូក្នុងបួនកាដ្រង់នៃប្លង់កូអរដោណេ។

# ការភ្ជាប់កូអរដោណេ

## សម្ភារៈបង្រៀន ៖ បៀ ធញ្ញជាតិមូលមានពណ៌ ដូចជាហ្វ្រូតលូប (Froot Loops)

ប្រើតែបៀប៉ុណ្ណោះ A—5; អាត់ស្មើនឹងមួយ សន្លឹកបៀផ្សេងទៀតស្មើនឹងតម្លៃដូចមាននៅក្នុងសន្លឹកបៀ។ បៀពណ៌ខ្មៅ (ជួង និង ប៊ីច) ជាវិជ្ជមាន ហើយបៀពណ៌ក្រហម (កឺ និងការ៉ូ)ជាអវិជ្ជមាន។
វត្ថុនៃល្បែងនេះគឺដាក់ហ្វ្រូតលូបចំនួនបីជាខ្សែត្រង់ ផ្តេក បញ្ឈរឬបញ្ឆៀងនៅលើការ៉ូកូអរដោណេ។
នៅទំព័របន្ទាប់នៃសៀវភៅនេះជាការ៉ូកូអរដោណេ។អ្នកអាចកាត់រូបនេះបិទនៅលើប្រអប់ទទេ(ឬសន្លឹកក្រដាសរឹង) ដើម្បីឲ្យរឹងមាំ។ អ្នកលេងម្នាក់ប្រើហ្វ្រូតលូបពណ៌ក្រហមសំរាប់ការចំណាំរបស់គេ ហើយម្នាក់ទៀតប្រើពណ៌បៃតង។

សាប់បៀហើយដាក់លើតុ។ អ្នកលេងA គូរបៀពីរសន្លឹក តម្លៃលេខក្នុងសន្លឹកបៀកំណត់កូអរដោណេ ដែលអ្នកលេង A ត្រូវដាក់ហ្វ្រូតលូបជាលើកដំបូង។ ឧទាហរណ៍ សន្លឹកបៀ 5ជួង និង 3ការ៉ូដែលបានគូរ។ កូអរដោណេអ្នកលេង A គឺ (5 –3)។
បន្ទាប់មកអ្នកលេងB គូរបៀពីរសន្លឹក និងដាក់ហ្វ្រូតលូបឲ្យត្រួតស៊ីគ្នានឹងកូអរដោណេ ។ ប្រសិនបើគូកូអរដោណេ ត្រូវបានគ្របដណ្តប់រួចហើយនោះ អ្នកលេងបាត់បង់វេន។

ការលេងបន្តឆ្លាស់គ្នាក្នុងទំរង់ដូចមុនរហូតដល់អ្នកលេងម្នាក់ដាក់ហ្វ្រូតលូបបីក្នុងជួរ។ ប្រសិនបើអ្នកលេងគ្មានលទ្ធភាព ដាក់ហ្វ្រូតមូលបីក្នុងជួរទេនោះ អ្នកលេងដែលគ្របដណ្តប់ចំចំណុចកូអរដោណេតែម្តង ឈ្នះ។

**បំរែបំរួលទីមួយ ៖** អ្នកកលេងអាចលេងបៀដែលគេគូដាក់តាមលំដាប់ណាមួយ។ ឧទាហរណ៍បានគូរ 5ជួង និង 3ការ៉ូ។ កូអរដោណេគឺ (5,–3) ឬ (–3, 5)។

**កំណត់ចំណាំ ៖** ធ្វើឲ្យប្រាកដថា កូនអ្នកកំពុងដាក់ហ្វ្រូតលូបនៅលើខ្សែប្រសព្វគ្នាតាងគូលំដាប់ត្រឹមត្រូវ។ ប្រើធញ្ញជាតិទាំងមូល ចំកណ្តាលឲ្យឃើញខ្សែពីរប្រសព្វគ្នា។ ជានិច្ចកាល លេខអ័ក្ស X (បន្ទាត់ដេក) ត្រូវនៅមុន អ័ក្ស Y (បន្ទាត់បញ្ឈរ)។

**ស្តង់ដាថ្នាក់ទីបួន : ពីជគណិត និងអនុគមន៍ 2.0**

សិស្សប្រើក្រឡាការ៉ូកូអរដោណេពីរទំហំដើម្បីតាងចំណុច។ និងខ្សែក្រាប និងតួលេខងាយៗ។

**ស្តង់ដាថ្នាក់ទីប្រាំ : ពីជគណិត និងអនុគមន៍ 1.4**

សិស្សកំណត់រក និងគូរក្រាបមានលំដាប់លេខមួយគូៗ នៅក្នុងបួនកាដ្រង់នៃប្លង់កូអរដោណេ។

# ការប្រកបក្រាបកូអរដោណេ

នៅលើទំព័របន្ទាប់នៃកូនសៀវភៅនេះ មានក្រាបកូអរដោណេអក្សរ។ អ្នកអាចកាត់រូបនេះចេញ ហើយយកវាបិទការដាក់នៅលើប្រអប់ទទេ(ឬបិទនៅលើក្រដាសរឹង) ដើម្បីឲ្យវារឹងមាំ។

## សកម្មភាពទី១ : សរសេរលេខកូដឈ្មោះអ្នក

ឲ្យកូនអ្នកសរសេរលំដាប់លេខមួយគូៗឆ្លើយតបទៅនឹងការប្រកបនាមឈ្មោះរបស់កូនអ្នក។

ឧទាហរណ៍ : Antonio—(-2,3) (2,1) (3,-1) (3,1) (2,1) (2,2) (3,1)

បន្ទាប់មកប្រាប់កូនឲ្យសរសេរលំដាប់លេខមួយគូៗឆ្លើយតបទៅនឹងការប្រកបនាមឈ្មោះរបស់កូនអ្នក។ សរសេរឈ្មោះនៃសមាជិកគ្រួសារអ្នក “សរសេរលេខកូដតាមលំដាប់លេខមួយគូៗ” និងឲ្យកូនអ្នកបកស្រាយលេខកូដឈ្មោះកូនរបស់អ្នក។

## សកម្មភាពទី២ : សរសេរលេខកូដពាក្យ

ឲ្យបញ្ជីពាក្យ (ពីការប្រកបពាក្យឬវាក្យសព្ទពាក្យក្នុងបញ្ជី កាសែត ឈ្មោះរដ្ឋ ទីក្រុង ។ល។) ហើយឲ្យកូនអ្នកកែពាក្យនីមួយៗ “លេខកូដលំដាប់លេខមួយគូៗ”។

បន្ទាប់មកឲ្យកូនអ្នក “សរសេរលេខកូដ” នូវពាក្យដែលកូនអ្នកជ្រើសរើស ហើយឲ្យទៅអ្នកបកស្រាយ លេខកូដ។

## សកម្មភាពទី៣ : សរសេរលេខកូដល្បះឬឃ្លា

កូនអ្នកសរសេរល្បះឬឃ្លាអក្សរសំងាត់ និង/ឬ បកស្រាយលេខកូដពីសៀវភៅសិក្សា សៀវភៅអាន កាសែត ឬទស្សនាវដ្ដី។

**កំណត់ចំណាំ :** ជានិច្ចកាល ចំនួនអ័ក្សអាប់ស៊ីស X (បន្ទាត់ដេក) ត្រូវចាត់ចូលក្នុងបញ្ជីដំបូង មុន ចំនួនអ័ក្សអាប់ស៊ីស Y (បន្ទាត់ឈរ)។

# ក្រាបកូអរដោណេតាមលំដាប់អក្សរ

(អ័ក្សអាប់ស៊ីស Y)



## ស្តង់ដាថ្នាក់ទីបួន : ស្ថិតិ ការវិភាគទិន្នន័យ និងប្រូបាប៊ីលីតេ 1.2

សិស្សកំណត់រកម៉ូតនៃសំណុំប្រភេទទិន្នន័យ និងម៉ូត មេដ្យាន និងចំនួនពិតប្រាកដផ្សេងទៀតសំរាប់សំណុំចំនួន។

## ស្តង់ដាថ្នាក់ទីប្រាំ : ស្ថិតិ ការវិភាគទិន្នន័យ និងប្រូបាប៊ីលីតេ

សិស្សស្គាល់បញ្ញត្តិ មធ្យម មេដ្យាន និងម៉ូត គណនា និងប្រៀបធៀបឧទាហរណ៍ងាយៗដើម្បីបង្ហាញពីភាពខុសៗគ្នា។

# មធ្យម មេដ្យាន និងម៉ូត

**សម្ភារះបង្រៀន :** ប័ណ្ណលេខ 1—9

**និយមន័យគណិតវិទ្យា : បីប្រភេទនៃមធ្យម**

- **មធ្យម :** គឺជាលទ្ធផលលេខដែលរកបានពីផលបូកនៃចំនួនលេខមួយក្រុមចែកនឹងចំនួនតួលេខ ទាំងនោះ។
- **មេដ្យាន :** គឺលេខស្ថិតនៅចំកណ្តាល នៃសំណុំលេខដែលបានរៀបលំដាប់ពីតូចបំផុតទៅធំបំផុត។ ចំពោះសំណុំលេខគូ មេដ្យានគឺជាមធ្យមនៃពីរលេខកណ្តាល។
- **ម៉ូត :** លេខឬចំនួនលេខដែលកើតមានញឹកញាប់នៅក្នុងសំណុំចំនួន។

**នីតិវិធី :**

1. សាប់ប័ណ្ណលេខ
2. គូរប័ណ្ណបីលេខ ហើយគណនាផលបូក និងកត់ត្រាទុក។
3. ធ្វើបន្តរហូតដល់អ្នកមានដប់ប្រាំផលបូក អ្នកត្រូវសាប់ប័ណ្ណឲ្យបានប្រាំដង។
4. រៀបលំដាប់ដប់ប្រាំផលបូកពីតូចបំផុតទៅធំបំផុត។
5. កំណត់រកថាតើផលបូកណាកើតឡើងញឹកញាប់ នោះគឺជាម៉ូត។
6. កំណត់រកថាតើផលបូកណាស្ថិតនៅចំកណ្តាលនៃលេខដែលបានរាយក្នុងបញ្ជីពីតូចបំផុតទៅធំ បំផុត។ ក្នុងករណីនេះ វាជាលេខទីប្រាំបី។
7. បូកផលបូកទាំងអស់បញ្ចូលគ្នា ហើយចែកផលបូកសរុបនឹងចំនួនដប់ប្រាំលេខ (លេខដប់ប្រាំផលបូក)។
8. កត់ព័ត៌មានអ្នកនៅលើក្រដាសកំណត់ត្រា។

**ឧទាហរណ៏ :**

**ផលបូករកឃើញគឺ :** 21, 19, 13, 6, 7, 13, 15, 17, 17, 21, 16, 17, 16, 17, 14

**ផលបូកលំដាប់ពីតូចបំផុតទៅធំបំផុតនោះគឺ :** 6, 7,13, 13, 14, 15, 16, 16, 17, 17, 17, 17, 19, 21, 21

**ម៉ូតគឺ :** 17... ដប់ប្រាំពីរកើតមានបួនដងក្នុងឧទាហរណ៏នេះ។

**មេដ្យានគឺ :** 16... ដប់ប្រាំមួយ ស្ថិតនៅកណ្តាលនៃលេខពីតូចបំផុតទៅធំបំផុតក្នុងបញ្ជី (លេខប្រាំបីពីខាង ឆ្វេង និងលេខប្រាំបីពីខាងស្តាំ)។

**មធ្យមគឺ:** 15... ផលបូកនៃលេខទាំងអស់គឺ225។ 225 គឺត្រូវចែកនឹង15 (ចំនួនលេខក្នុងបញ្ជី: $225 \div 15 = 15$)។

**កំណត់ចំណាំ :** ឲ្យកូនអ្នករំលឹកនីតិវិធីនេះបីឬច្រើនដង រហូតដល់កូនអ្នកអាចស្រាយបំភ្លឺចំណេះដឹងនៃវាក្យសព្ទ (មធ្យម មេដ្យាន ម៉ូត) និងទេព្យកោសល្យនៃនីតិវិធីនេះ។

សំណុំលេខខ្លះអាចមានលទ្ធភាពមានម៉ូតច្រើនជាងមួយ នៅពេលលេខខ្លះកើតមានភាពស្មើគ្នាញឹកញាប់។

មធ្យម និង/ឬ មេដ្យាន និង/ឬ ម៉ូតអាចមានលទ្ធភាពលេខដូចគ្នា។

មធ្យម មេដ្យាន ម៉ូត

ក្រដាសកត់ត្រា

| ផលបូកប័ណ្ណបីលេខ |
| --- |
| |
| ផលបូកលំដាប់ពីតូចបំផុតទៅធំបំផុត |
| |
| ម៉ូត : |
| មេដ្យាន : |
| លេខមធ្យម : |

**ស្តង់ដាថ្នាក់ទីបួន ៖ រង្វាស់រង្វាល់ និងធរណីមាត្រ3.0**

សិស្សស្រាយបំភ្លឺការយល់ដឹងពីវត្ថុធរណីមាត្រស្វូលីត និងប្លង់ ហើយប្រើចំណេះដឹងនេះដើម្បីបង្ហាញពីទំនាក់ទំនង និងដោះស្រាយចំណោទ។

**ស្តង់ដាថ្នាក់ទីប្រាំ ៖ រង្វាស់រង្វាល់ និងធរណីមាត្រ ២។០**

សិស្សកំណត់រក ពណ៌នា និងចំណាត់អនចលនទ្រព្យ និងទំនាក់ទំនងរវាងរូបភាពធរណីមាត្រស្វូលីត និងប្លង់។

# ការប្រមូលផ្តុំធរណីមាត្រ

**សម្ភារៈបង្រៀន ៖** ប្រអប់ទទេ ជ័រកាវ ស្កុត

វត្ថុនៃល្បែងនេះគឺផ្គូរផ្គងពាក្យបច្ចេកទេសធរណីមាត្រទៅនឹងរូបភាព។

នៅទំព័របន្ទាប់នៃកូនសៀវភៅនេះមានរូបនិងបញ្ជីពាក្យបច្ចេកទេសធរណីមាត្រ។កាត់ជុំវិញរូបចតុកោណកែង។

បិទការឬស្កុតនៃបញ្ជីនេះទៅនឹងផ្ទៃប្រអប់ នៅពេលការស្ងួតផ្ងារប្រអប់មកវិញ ធ្វើយ៉ាងណាឲ្យឃើញរូបភាព។ រូបភាពត្រូវនៅម្ខាង ហើយរូបនិងពាក្យបច្ចេកទេសធរណីមាត្រត្រូវនៅម្ខាងនៃប្រអប់។

ផ្ងារប្រអប់ខាងរូប និងពាក្យបច្ចេកទេសធរណីមាត្រ ហើយកាត់រូបចតុកោណជាចំណែកៗតាមខ្សែ។

ដើម្បីលេង **ការប្រមូលផ្តុំធរណីមាត្រ ៖**

1. ផ្ងាប់រូប និងពាក្យបច្ចេកទេសធរណីមាត្រ (អ្នកអាចមើលឃើញរូបភាព)។
2. ច្របល់កំណាត់រូបទាំងនេះ។
3. ផ្កាប់មុខកំណាត់រូបទាំងនោះក្នុងជួរ ដោយមានប្រាំពីរកំណាត់ជាបួនជួរ(បួនជួរនៃប្រាំពីរកំណាត់)។
4. ផ្ងារកំណាត់រូបពីរ។ ប្រសិនបើពួកគេបានផ្គូរផ្គងត្រូវយកកំណាត់រូបទាំងនោះចេញពីផ្ទៃលេង។ ប្រសិនបើពួកគេមិនបានផ្គូរផ្គង ត្រូវដាក់វាទៅកន្លែងដើមដោយផ្កាប់រូប។
5. បន្តការលេងរហូតដល់រូប និងពាក្យបច្ចេកទេសធរណីមាត្រទាំងដប់ប្រាំគូរបានផ្គូរផ្គងរួចរាល់។
6. នៅពេលលេងតទល់នឹងគូបដិបក្ស អ្នកឈ្នះបង្កើតការផ្គូរផ្គងបានច្រើនបំផុត។
7. នៅពេលលេងតទល់បានតែខ្លួនឯង ព្យាយាមលេងឲ្យលឿនបំផុតដើម្បីចាប់គូរការផ្គូរផ្គងទាំងអស់នេះ។
8. ត្រួតពិនិត្យឲ្យឃើញ ប្រសិនបើការផ្គូរផ្គងនេះបានត្រឹមត្រូវដោយផ្ងាប់កំណាត់រូបទីមួយៗ ដើម្បីបង្កើតរូបភាពប្រអប់។

## ឧទាហរណ៍

ម្ខាងធរណីមាត្រ

| | |
|---|---|
| ត្រីកោណសមបាត |  |
| ត្រីកោណកែង |  |
| ចតុកោណព្នាយ |  |

ម្ខាងរូបភាព



ស្តង់ដាថ្នាក់ទី៤ ៖ រង្វាស់រង្វាល់ និងធរណីមាត្រ 1.3

សិស្សយល់ពីចតុកោណកែងដែលមានបរិមាត្រដូចគ្នាអាចមានផ្ទៃឡ្រាខុសៗគ្នា។

ស្តង់ដាថ្នាក់ទី៥ ៖ រង្វាស់រង្វាល់ និងធរណីមាត្រ ១។០

សិស្សយល់ និងគណនាមាឌ និងផ្ទៃក្រឡានៃវត្ថុងាយៗ។

## បរិមាត្រចតុកោណកែងដូចគ្នា-តើមានអ្វីកើតឡើងចំពោះផ្ទៃក្រឡា?

សម្ភារៈបង្រៀន ៖ សន្លឹកក្រដាសក្រឡាការ៉េមួយសង្ទីម៉ែត្រ ខ្មៅដៃឬខ្មៅដៃពណ៌

នៅលើក្រដាសក្រឡាការ៉េមួយសង្ទីម៉ែត្រដែលបង្ហាញនៅទំព័របន្តបន្ទាប់មានគំនូរចតុកោណកែងខុសៗគ្នាចំនួនដប់ ដែលក្នុងនោះមាន បរិមាត្រនីមួយៗ 40សម។ ប្រើរូបមន្តសំរាប់រកបរិមាត្រនៃចតុកោណកែងមួយ ដែលមានបណ្តោយពីរដង បូកនឹងទទឹងពីរដង (2បណ្តោយ + 2ទទឹង = បរិមាត្រ) ដើម្បីបញ្ជាក់ឲ្យដឹងថា បរិមាត្រនៃចតុកោណកែងទាំងអស់ស្មើនឹង 40សម។

អ្នកអាចគូរចតុកោណកែងខុសៗគ្នាចំនួនដប់ដែលមានបរិមាត្រ 40សម។ អ្នកអាចប្រើឆាតជាជំនួយ ដើម្បីឲ្យអ្នកអាចរកទំហំនៃចតុកោណនីមួយៗក្នុងវិធីជាប្រព័ន្ធ។ឧទាហរណ៍ពីរដំបូងបានធ្វើរួចហើយសំរាប់អ្នក។

| | បណ្តោយ | ទទឹង |
|---|---|---|
| 1 | 19 សម | 1សម |
| 2 | 18សម | 2សម |
| 3 | | |
| 4 | | |
| 5 | | |
| 6 | | |
| 7 | | |
| 8 | | |
| 9 | | |
| 10 | | |

នៅពេលប្រវែងបណ្តោយថយចុះមួយសង្ទីម៉ែត្រ (1សម) តើមានអ្វីកើតឡើងចំពោះប្រវែងទទឹង?

ឥឡូវនេះប្រើប្រាស់រូបមន្តសំរាប់រកផ្ទៃក្រឡាចតុកោណកែង បណ្តោយគុណនឹងទទឹង (បណ្តោយ × ទទឹង = ផ្ទៃ ) ដើម្បីរកផ្ទៃក្រឡានៃចតុកោណកែងនីមួយៗ។ អ្នកក៏អាចរាប់ការេទាំងអស់នៅក្នុងចតុកោណកែងលើក្រដាសក្រឡាៗ ដែលអ្នកគូរដើម្បីបញ្ជាក់លទ្ធផលរបស់អ្នក។

ប្រើសន្លឹកកំណត់ត្រាដើម្បីបង្ហាញការរកឃើញរបស់អ្នក។ ត្រូវចងចាំថា ទំហំបរិមាត្រត្រូវវាស់ដោយឯកតាគូសបន្ទាត់ (ក្នុងករណីនេះគឺ សង្ទីម៉ែត្រ-សម) ទន្ទឹមនឹងនោះ ទំហំផ្ទៃក្រឡាត្រូវវាស់ដោយឯកតាជាការេ (ក្នុងករណីនេះគឺសង្ទីម៉ែត្រការេ-សម$^2$)។ ឧទាហរណ៍ពីរដំបូងបានធ្វើរួចហើយសំរាប់អ្នក។

| | បណ្តោយ | ទទឹង | បរិមាត្រ | ផ្ទៃក្រឡា |
|---|---|---|---|---|
| **1** | **19 សម** | **1 សម** | **40 សម** | **19 សម$^2$** |
| **2** | **18 សម** | **2 សម** | **40 សម** | **36 សម$^2$** |
| **3** | | | | |
| **4** | | | | |
| **5** | | | | |
| **6** | | | | |
| **7** | | | | |
| **8** | | | | |
| **9** | | | | |
| **10** | | | | |

ថ្វីត្បិតតែបរិមាត្រមាន 40 សម(ថេរ)ដូចគ្នាក៏ដោយ តើមានអ្វីកើតឡើងចំពោះផ្ទៃក្រឡា? បណ្តោយកាន់តែខិតជិតទៅៗរហូតដល់ស្មើនឹងប្រវែងទទឹង តើមានអ្វីកើតឡើងចំពោះផ្ទៃក្រឡា?

កំណត់ចំណាំ: បរិមាត្រ: នៅពេលដែលប្រវែងបណ្តោយថយចុះ 1សម នោះប្រវែងទទឹងនឹងកើន 1សម។ 10ចតុកោណកែងត្រូវមានទំហំជាបន្តបន្ទាប់ : 19សម × 1សម , 18សម × 2សម ,17សម × 3សម , 16សម × 4សម19សម , 15សម × 5សម ,14សម × 6សម ,13សម × 7សម ,12សម × 8សម ,11សម × 9សម , 10សម × 10សម។

ត្រូវចងចាំថា ការេគឺជាប្រភេទពិសេសនៃចតុកោណកែង។ ប្រសិនបើកូន អ្នកមានការលំបាកក្នុងការប្រើប្រាស់រូបមន្តសំរាប់រកបរិមាត្រនៃចតុកោណកែង ត្រូវអនុញ្ញាតិឲ្យពួកគេបន្ថែមការវាស់ ជ្រុងទាំងបួននៃចតុកោណកែង ដើម្បីរកបរិមាត្រនោះ។

ផ្ទៃក្រឡានៃ 10ចតុកោណកែងមានតាមលំដាប់ : 19សម$^2$, 36សម$^2$, 51សម$^2$, 64សម$^2$, 75សម$^2$, 84សម$^2$, 91សម$^2$,96សម$^2$, 99សម$^2$, 100សម$^2$ ។

ផ្ទៃក្រឡានៃចតុកោណកែងកើនឡើង នៅពេលដែលប្រវែងបណ្តោយកាន់តែខិតជិតទៅៗរហូតដល់ស្មើនឹងប្រវែងទទឹង។ ចតុកោណដែលមានផ្ទៃក្រឡាធំជាងគេគឺជាការេ។ សាកល្បងធ្វើសកម្មភាពនេះជាមួយចតុកោណផ្សេងទៀតៗដែលមានបរិមាត្រខុសៗគ្នាថេរ។

**ស្តង់ដាថ្នាក់ទីបួន : រង្វាស់រង្វាល់ និងធរណីមាត្រ 3.0**
សិស្សស្រាយបំភ្លឺការយល់ដឹងពីវត្ថុធរណីមាត្រក្នុងប្លង់ និងសូលីត។

**ស្តង់ដាថ្នាក់ទីប្រាំ : រង្វាស់រង្វាល់ និងធរណីមាត្រ ១។២**
សិស្សសង់គូប និងប្រអប់ចតុកោណកែងគំរូ ពីរទំហំ។

# តើសំណាញ់ណាមួយធ្វើគូបបាន?

**សម្ភារៈបង្រៀន :** សំណាញ់ និងកន្ត្រៃ

សំណាញ់គឺការតាងពីរទំហំនៃរូបសូលីតបីទំហំ។ កាត់សំណាញ់ចេញពីទំព័រនេះ និងទំព័របន្ទាប់នៃកូន សៀវភៅ។ សំណាញ់ខ្លះអាចធ្វើគូបបាន។ បត់ដោយប្រុងប្រយ័ត្នដើម្បីឲ្យឃើញថា តើសំណាញ់ណាខ្លះបង្កើត បានគូប។






**កំណត់ចំណាំ** ៖ សំណាញ់ដូចខាងក្រោមបង្កើតបានគូបនៅពេលបត់វា ៖ លេខ 2 5 6 8 10 13 14 15 និង 16។

**ស្តង់ដាថ្នាក់ទីបួន ៖ រង្វាស់រង្វាល់ និងធរណីមាត្រ 3.0**
សិស្សស្រាយបំភ្លឺការយល់ដឹងពីវត្ថុធរណីមាត្រក្នុងប្លង់ និងសូលីត។
**ស្តង់ដាថ្នាក់ទីប្រាំ ៖ រង្វាស់រង្វាល់ និងធរណីមាត្រ ១។២**
សិស្សសង់គូប និងប្រអប់ចតុកោណកែងគំរូ ពីរទំហំ។

# តើសំណាញ់ណាមួយធ្វើគូបបាន?

**សម្ភារៈបង្រៀន ៖** សំណាញ់ និងកន្ត្រៃ

សំណាញ់គឺការតាងពីរទំហំនៃរូបសូលីតបីទំហំ។ កាត់សំណាញ់ចេញពីទំព័រនេះ និងទំព័របន្ទាប់នៃកូន សៀវភៅ។ សំណាញ់ខ្លះអាចធ្វើគូបបាន។ បត់ដោយប្រុងប្រយ័ត្នដើម្បីឲ្យឃើញថា តើសំណាញ់ណាខ្លះបង្កើត បានគូប។

## ស្តង់ដាថ្នាក់ទីបួនៈ រង្វាស់រង្វាល់ និងធរណីមាត្រ 3.5

សិស្សយល់ពីមុំ ៩០° ១៨០° ២៧០° ៣៦០° ដែលបង្កើតបានជាប្រភាគ $\frac{1}{4}$, $\frac{1}{2}$, $\frac{3}{4}$ និង ប្រភាគស្មើនឹង ១(ទាំងមូល)។

## ស្តង់ដាថ្នាក់ទីនប្រាំៈ រង្វាស់រង្វាល់ និងធរណីមាត្រ ២។១

សិស្សអាចវាស់មុំ កំណត់មុំ និងគូរមុំ។

# *ការប្រណាំងមុំនៅលើមុខនាឡិកា*

## សម្ភារៈបង្រៀនៈ ស្តេកេតទី ក្តារល្បែងមុខនាឡិកា ប័ណ្ណវាស់ដឺក្រេ ប្រអប់

វត្ថុនៃល្បែងនេះគឺដំបូងបង្អស់បំពេញមុំ 360° នៅលើក្តារល្បែងមុខនាឡិកា។

នៅទំព័របន្ទាប់នៃកូនសៀវភៅនេះមានបញ្ជីរាយប័ណ្ណដឺក្រេដែលមានរង្វាស់ខុសៗគ្នា។ បិទបញ្ជីប័ណ្ណដឺក្រេនេះ នៅលើផ្ទៃប្រអប់។

កាត់ជុំវិញគែមប័ណ្ណដឺក្រេ។

ដើម្បីលេងប្រណាំងមុំៈ

9. អ្នកលេងត្រូវមានមុខនាឡិកាម្នាក់មួយៗ។
10. សាប់ប័ណ្ណរង្វាស់ដឺក្រេមុំ ហើយដាក់វានៅលើតុ។
11. អ្នកលេងកាច់សរសៃស្តេកេតទីជាពីរកំណាត់ស្មើគ្នា ដើម្បីឲ្យកំណាត់សរសៃស្តេកេតទីអាចឈានពីចំណុចកណ្តាលទៅដល់លេខដប់ពីនៃមុខនាឡិកា។
12. អ្នកលេងម្នាក់ៗដាក់ស្តេកេតទីមួយសរសៃនៅលើមុខនាឡិកាលាតសន្ធឹងពីចំណុចកណ្តាលទៅលេខដប់ពីរ។
13. បន្ទាប់មកអ្នកលេងជ្រើសរើសប័ណ្ណរង្វាស់ដឺក្រេមុំមួយ ហើយបង្កើតរង្វាស់មុំប្រើសរសៃស្តេកេតទី ផ្សេងទៀត ដោយដាក់ចុងម្ខាងនៅចំកណ្តាល និងចុងម្ខាងទៀតឲ្យសមស្របនឹងលេខនាឡិកា។
14. លេខនាឡិកានីមួយៗតាងមុំ 30° ធ្វើចលនាជុំវិញផ្ទៃនៃរង្វង់ ពីព្រោះមុំ 360° (ចំនួនដឺក្រេមុំ ក្នុងរង្វង់) ចែកនឹងដប់ពី (លេខនាឡិកា) ស្មើនឹង 30° (360° ÷ 12 = 30°) ។
15. បន្ទាប់មកអ្នកលេងគូរប័ណ្ណលើកទីពីរ ហើយបូករង្វាស់មុំថ្មីបន្ថែមលើរង្វាស់មុំចាស់ដោយរំកិល សរសៃស្តេកេតទីលើកទីពីរម្តងទៀតនៃបញ្ជីដឺក្រេមុំនៅលើប័ណ្ណរង្វាស់ដឺក្រេមុំ។
16. ឧទាហរណ៍ អ្នកលេងគូរប័ណ្ណមុំ 30° ហើយរំកិលសរសៃស្តេកេតទីទៅលេខ 1។ ការរំកិលបន្ទាប់ អ្នកលេងគូរប័ណ្ណមុំ 90° រំកិលសរសៃស្តេកេតទីទៅលេខ 4 ពីព្រោះលេខ 4គឺមុំ 90° រាប់ចាប់ពីលេខ 1 និង 30° + 90° = 120° ។ លេខ 4 គឺមុំ 120° រាប់ចាប់ពីលេខ 12។
17. អ្នកលេងបន្តគូរប័ណ្ណរង្វាស់ដឺក្រេមុំរហូតដល់អ្នកលេងម្នាក់ឈ្នះ ដោយមានលទ្ធភាពអាចរំកិល សរសៃស្តេកេតទីបានមុំសរុប 360° ដោយរំកិលរហូតដល់ទីដៅលើលេខ 12វិញ។
18. ប្រសិនបើអ្នកលេងគូរប័ណ្ណដឺក្រេមុំដែលជាហេតុអ្នកលេងរំកិលកាត់លេខ 12(360°) នោះអ្នកលេង ត្រូវតែរំកិលសរសៃស្តេកេតទីបកក្រោយវិញតាមបញ្ជីរង្វាស់ដឺក្រេមុំនៅលើប័ណ្ណដែលគេបានគូរ។
19. ឧទាហរណ៍ អ្នកលេងម្នាក់ស្ថិតនៅលេខ 11 គឺមុំ 30° ពីលេខ 12 ប៉ុន្តែគេគូរប័ណ្ណរង្វាស់ ដឺក្រេមុំ 60° ។នោះជាហេតុដែលសរសៃស្តេកេតទីរំកិលទៅកាត់លេខ 12 (360°)។ ហេតុដូច្នេះ អ្នកលេងដែលប័ណ្ណមានមំ60° នោះ ត្រូវតែរំកិលសរសៃស្តេកេតទីបកក្រោយមកនៅលេខ 9វិញ។



| | | | |
|---|---|---|---|
| 30° | 30° | 30° | 30° |
| 30° | 30° | 30° | 30° |
| 30° | 30° | 30° | 30° |
| 60° | 60° | 60° | 60° |
| 60° | 60° | 60° | 60° |
| 60° | 60° | 60° | 60° |
| 90° | 90° | 90° | 90° |

**កំណត់ចំណាំ:** 3 ឲ្យកូនរបស់អ្នកប្រាប់តើមុំណាមួយដែលផ្គុំបានជាល្បែងលេង

មុំស្រួច តូចជាង $= 90^0$

មុំកែង $= 90^0$ ត្រឹម

មុំទាល $=$ ធំជាង $90^0$ និងតូចជាង $180^0$

មុំលាត $= 180^0$ ត្រឹម

មុំរេផ្លិច $=$ ធំជាង $180^0$ និងតូចជាង $360^0$

**ស្តង់ដាថ្នាក់ទីបួន និងទីប្រាំ : វិចារគណិតវិទ្យា 2.4**

សិស្សផ្តល់ចម្លើយច្បាស់លាស់ និងសមហេតុផល ដោយប្រើប្រាស់សញ្ញាណ និងពាក្យបច្ចេកទេសគណិតវិទ្យាសមស្រប និងភាសាច្បាស់លាស់។

# ការយោលជុំវិញនាឡិកា

**សម្ភារៈ** បៀមួយហ្វូ ក្រឡាចតុរង្គ កាក់ឬហ្វឺត មុខនាឡិកា

ដកសន្លឹកបៀរូបស្តេច ក្រមុំ និងកំឡោះ។ សន្លឹកអាត់មានតម្លៃស្មើនឹងមួយ និងសន្លឹកបៀផ្សេងៗទៀត មានតម្លៃដូចនឹងសន្លឹកបៀរបស់វា។

នៅទំព័របន្ទាប់នៃកូនសៀវភៅនេះមានរូបមុខនាឡិកា។ អ្នកអាចកាត់រូបនេះចេញ ហើយបិទវានឹងជ័រការ នៅលើប្រអប់ទទេ (ឬនៅលើក្រដាសកាតុង)ដើម្បីឲ្យរឹងមាំ។

វត្ថុនៃល្បែងនេះគឺអ្នកលេងទីមួយគ្រប(បាំង)លេខនាឡិកាទាំងដប់ពីរ ដែលប្រើក្រឡាចតុរង្គ កាក់ឬហ្វឺត។

សាប់បៀក្នុងហ្វូ។ បើកបៀបីសន្លឹកខាងលើ។ អ្នកលេងប្រើប្រាស់ប្រមាណវិធីណាមួយនៃប្រមាណវិធីគណិត វិទ្យាទាំងបួន (បូក ដក គុណ ចែក)ដើម្បីបង្កើតសមីការ និងចម្លើយដែលស្មើនឹងលេខដែលមិនបានគ្រប (ឬបាំង)នៅលើមុខនាឡិកា។

ឧទាហរណ៍ៈ លេខ 3, 4, និង 6 បានបង្ហាញ។ អ្នកលេង A បង្កើតសមីការ 3 + 4 – 6 = 1 និងគ្របលេខមួយនៅលើមុខនាឡិការបស់គាត់។ អ្នកលេង B បង្កើតសមីការ 6 x 4 ÷ 3 = 8 ហើយគ្របលេខប្រាំបីនៅលើមុខនាឡិការបស់គាត់។ សមីការផ្សេងៗទៀតអាចមានៈ 6 + 4 – 3 = 7, 6 ÷ 3 x 4 = 8, 4 x 3 – 6 = 6 ។ល។

ក្រោយពីអ្នកលេងបានបង្កើតសមីការ និងគ្របចម្លើយនៅលើមុខនាឡិកា បៀបីសន្លឹកថ្មីបានបើក ហើយការលេងបន្តដូចពីមុន។

អ្នកលេងម្នាក់ៗត្រូវបង្កើតសមីការតែមួយដែលត្រូវអនុញ្ញាតិឲ្យគ្របលេខនៅលើមុខនាឡិកា។ អ្នកលេងទីមួយ មានភាពម្ចាស់ការដើម្បីបង្កើតសមីការមួយ ដែលសមីការនោះ និងសមីការបន្តបន្ទាប់ត្រូវតែខុសៗគ្នា (មិនចម្លងដូចគ្នាទេ)។ ប្រសិនបើអ្នកលេងបង្កើតសមីការមួយ ដែលមានចម្លើយគ្របនៅលើមុខនាឡិកា រួចទៅហើយ នោះអ្នកលេងត្រូវព្យាយាមបង្កើតសមីការមួយដែលមានចម្លើយមិនបានគ្របលេខ។ ប្រសិន បើគ្មានបង្កើតសមីការ នោះអ្នកលេងបាត់បង់វេន។ ការលេងបន្តរហូតដល់អ្នកលេងម្នាក់ គ្របលេខពី 1—12 ដោយជោគជ័យនៅលើមុខនាឡិកា ហើយឈ្នះ ល្បែងនេះ។

**បំរែបំរួលទីមួយៈ** អ្នកលេងអាចបង្កើតសមីការបានច្រើនខុសៗគ្នាតាមលទ្ធភាពអាចធ្វើបានជាមួយសន្លឹកបៀបី សន្លឹកគ្របលើលេខមុខនាឡិកាក្នុងពេលវេននីមួយៗ។

**បំរែបំរួលទីពីរៈ** ប្រើប្រាស់សន្លឹកបៀបួនឬច្រើនក្នុងពេលមួយដើម្បីប្រឹងប្រែងលេងកាន់តែខ្លាំង និងបាន សមីការកាន់តែស្មុគស្មាញ។

**កំណត់ចំណាំៈ** ឲ្យកូនសរសេរសមីការដែលបានបង្កើត។ ជំរុញការប្រើសញ្ញាវង់ក្រចកដើម្បីបញ្ជាក់ខាងមុខនូវប្រមាណវិធីតាមលំដាប់លំដោយ ។ ឧទាហរណ៍ៈ (2 x 3) – 1 = 5, but 2 x (3 – 1) = 4 ។

**ស្តង់ដាថ្នាក់ទីបួន និងទីប្រាំ : គណិតវិទ្យាបែបពិចារណា2.1**

សិស្សប្រើការប៉ាន់ស្មានដើម្បីផ្ទៀងផ្ទាត់លទ្ធផលដែលបានគណនាប្រកបដោយភាពពិចារណា

# ប្រមាណវិធីប៉ាន់ស្មាន

**សម្ភារះបង្រៀន :** នាឡិកាចុចកំណត់នាទី ប្រអប់ ជ័រការ កន្ត្រៃ

**នីតិវិធី :**

- នៅសន្លឹកទំព័របន្តបន្ទាប់ បិទប័ណ្ណប្រមាណវិធីគុណ និងចែកដែលអ្នកត្រូវរក នៅសងខាងនៃប្រអប់។
- កាត់ប័ណ្ណនេះចេញ

**ជុំទីមួយ : ប្រមាណវិធីគុណ**

- សាប់ប័ណ្ណប្រមាណវិធីគុណ ហើយដាក់វានៅលើតុ។
- អ្នកលេងឆ្លាស់ផ្លូវផ្តង់រកផលិតផលប៉ាន់ស្មាននៃចំណោទវិធីគុណ។
- អ្នកលេងមានពេលប្រាំនាទីដើម្បីផ្លូវផ្តងរកផលិតផលប៉ាន់ស្មាននៃចំណោទវិធីគុណ។
- អ្នកលេងបានពិន្ទុមួយពីការផ្លូវផ្តងប៉ាន់ស្មាននីមួយៗ។

**ជុំទីពីរ : ប្រមាណវិធីគុណ**

- អ្នកលេងមានពេលដប់នាទីរកផលិតផលជាក់ស្តែងដែលជាចម្លើយការផ្លូវផ្តងប៉ាន់ស្មានដែលបានរកឃើញនៅជុំទីមួយ។
- អ្នកលេងបានពិន្ទុមួយពីការផ្លូវផ្តងប៉ាន់ស្មាននីមួយៗ។

**ការឈ្នះ :** អ្នកលេងដែលបានពិន្ទុធំបំផុតក្រោយជុំទីមួយ និងជុំទីពីគឺជាអ្នកឈ្នះ។

**ជុំទីមួយ : ប្រមាណចែក**

- សាប់ប័ណ្ណប្រមាណវិធីចែក ហើយដាក់វានៅលើតុ។
- អ្នកលេងឆ្លាស់ផ្លូវផ្តង់រកផលចែកប៉ាន់ស្មាននៃចំណោទវិធីចែក។
- អ្នកលេងមានពេលប្រាំនាទីដើម្បីផ្លូវផ្តងរកផលចែកប៉ាន់ស្មាននៃចំណោទវិធីចែក។
- អ្នកលេងបានពិន្ទុមួយពីការផ្លូវផ្តងប៉ាន់ស្មាននីមួយៗ។

**ជុំទីពីរ : ប្រមាណវិធីចែក**

- អ្នកលេងមានពេលដប់នាទីរកផលចែកជាក់ស្តែងដែលជាចម្លើយការផ្លូវផ្តងប៉ាន់ស្មានដែលបានរកឃើញនៅជុំទីមួយ។
- អ្នកលេងបានពិន្ទុមួយពីការផ្លូវផ្តងផលិតផលជាក់ស្តែងនីមួយៗ។

**ការឈ្នះ :** អ្នកលេងដែលបានពិន្ទុធំបំផុតក្រោយជុំទីមួយ និងជុំទីពីគឺជាអ្នកឈ្នះ។

**បំរែបំរួល :**

- សាប់ប័ណ្ណប្រមាណវិធីគុណ និងចែកទាំងអស់ ហើយដាក់នៅលើតុជាមួយគ្នា។
- លេងដូចខាងលើ លើកលែងតែអ្នកលែងបួនជុំ (ពីរជុំលេងប្រមាណវិធីគុណ និងពីរជុំវិធីចែក)។
- អ្នកឈ្នះគឺអ្នកលេងបានពិន្ទុធំបំផុតក្រោយបួនជុំបានបញ្ចប់។

ប្រមាណវិធីគុណ

| ចំណោទ | ចម្លើយប៉ាន់ស្មាន | ចម្លើយជាក់ស្តែង |
|---|---|---|
| 12 x 13 = | 100 | 156 |
| 31 x 11 = | 300 | 341 |
| 23 x 19 = | 400 | 437 |
| 29 x 19 = | 600 | 551 |
| 38 x 22 = | 800 | 836 |
| 33 x 27 = | 900 | 891 |

RbmaNviZIEck

| ចំណោទ | ចម្លើយប៉ាន់ស្មាន | ចម្លើយជាក់ស្តែង |
|---|---|---|
| 221 ÷ 17 = | 10 | 13 |
| 288 ÷ 18 = | 15 | 16 |
| 361 ÷ 19 = | 20 | 19 |
| 486 ÷ 18 = | 25 | 27 |
| 644 ÷ 23 = | 30 | 28 |
| 2226 ÷ 53 = | 40 | 42 |

## ថ្នាក់ទី ៥ និងទី ៤ ៗ ការពិតនៃមូលដ្ឋានប្រមាណវិធីគុណ និងចែក ត្រីកោណពិត

## សម្ភារៈបង្រៀនៈ ប័ណ្ណត្រីកោណពិត ប្រអប់ទទេ កន្ត្រៃ ជ័រកាវ

ត្រីកោណពិតអាចជាមធ្យោបាយកាន់តែមានប្រសិទ្ធភាពនៃការចងចាំប្រមាណវិធីគុណពិត ពីព្រោះសង្កត់ធ្ងន់ លើគ្រួសារពិត។ ចំនួនបីទាក់ទងនឹងប្រមាណវិធីគុណពិត ត្រូវបានដាក់នៅជ្រុងនីមួយៗនៃត្រីកោណ(ពីរកត្តា និងផលិតផលមួយ) ផលិតផលគឺស្ថិតនៅកំពូលនៃត្រីកោណ និងកំណត់សំគាល់ដោយសញ្ញាផ្កាយ(*)។

នៅទំព័របន្តបន្ទាប់នៃសៀវភៅនេះមានបង្ហាញទំព័រប្រមាណវិធីគុណ/ចែក ត្រីកោណពិត។ កាត់ជុំវិញទំរង់ ត្រីកោណ។ បិទការ ឬស្កុតរូបកាត់នេះនៅលើប្រអប់ទទេ។ បន្ទាប់មកកាត់រូបបំណែកត្រីកោណនីមួយៗ។

ដើម្បីប្រើត្រីកោណពិត ៖

1. យកម្រាមដៃឬម្រាមមេដៃបិទលេខណាមួយនៅលើត្រីកោណ។
2. បង្ហាញត្រីកោណឲ្យកូនអ្នកមើល ដោយបាំងលេខដែលបិទម្រាមដៃនោះកុំឲ្យឃើញ។
3. ឲ្យកូនអ្នកឆ្លើយប្រាប់អ្នកថាតើលេខដែលបិទនោះជាលេខអ្វី។

**ឧទាហរណ៍ ៖**




គ្រួសារពិតគឺ ៖ 2 x 4 = 8.

អ្នកយកម្រាមមេដៃបិតលេខ 4។

កូនអ្នកគិត “តើ 2 គុណនឹងប៉ុន្មាន ស្មើនឹង 8?”

កូនចងចាំថាលេខដែលបាត់នោះគឺលេខ 4។

កូនក៏ឆ្លើយថា “លេខដែលបិទនោះគឺ លេខ 4ព្រោះ 2 គុណនឹង 4 ស្មើប្រាំបី ”។

**កំណត់ចំណាំ** ៖ បង្ហាញកូនអ្នកសកម្មភាពត្រីកោណដោយជាដំបូងគ្របផលិតផល។ បន្ទាប់មក នៅពេលកូនអ្នកស្រាយបំភ្លឺចំណេះដឹងពីផលិតផល គ្របកត្តាណាមួយ។ ទីបញ្ចប់គ្របលេខនៅជ្រុងណាក៏ដោយតាមការជ្រើស។

ក្រោយពីបានលេងជាមួយត្រីកោណពិតមួយស្របក់មក អ្នកអាចជ្រើសរើសបញ្ឈប់កាលេងត្រីកោណពិតងាយៗ ធ្វើដូច្នេះដើម្បីឲ្យកូនអ្នកទទួលយកបន្ថែមនូវការអនុវត្តការពិតលំបាកៗ (តួយ៉ាងដូចជា 6 7 8 និង 9)។ ឲ្យកូនអ្នកកត់ត្រាគ្រួសារពិត ជាសមីការនៅលើសន្លឹកក្រដាសដោយឡែក ដើម្បីពង្រឹងផ្លាស់ប្តូរកម្មសិទ្ធិនៃប្រមាណវិធីគុណ (ឧទា. 2 x 4 = 8 និង 4 x 2 = 8)។

កូនអ្នកបានស្រាយបំភ្លឺទេព្យកោសល្យនៃត្រីកោណពិតពីទស្សនៈវិស័យប្រមាណវិធីគុណ អ្នកអាចប្រើវាដើម្បីចាប់ផ្តើមបង្ហាញប្រមាណវិធីចែកពិត (ឧទា. 8 ÷ 2 = 4)ម្តងវិញ។

# ការប្តូរង្វាស់រង្វាល់

ចូរបំពេញចន្លោះខាងក្រោម។ វាមានសារៈសំខាន់ណាស់ដែលអ្នកដឹង និងមានលទ្ធភាពអនុវត្តការ ប្តូររង្វាស់រង្វាល់ ជារួម។

១. ១ ហ្វូត =_____អ៊ិញ

២. ១ យ៉ាដ =_____អ៊ិញ

៣. ១ យ៉ាដ =_____ហ្វីត

៤. ១ ម៉ែត =_____សង្ទីម៉ែត

៥. ១ គីឡូម៉ែត =_____ម៉ែត

៦. ១ ខាប់ =_____អោន្ស

៧. ១ ភិន =_____ខាប់

៨. ១ ក្វាត =_____ ភិន

៩. ១ កាឡុង =_____ ក្វាត

១០. ១ លីត =_____មីលីលីត

១១. ១ ផោន =_____អ៊ាន់

១២. ១ គីឡូក្រាម =_____ក្រាម

១៣. ១ នាទី =_____វិនាទី

១៤. ១ ម៉ោង =_____នាទី

១៥. ១ ថ្ងៃ =_____ម៉ោង

១៦. ១ សប្តាហ៏ =_____ថ្ងៃ

១៧. ១ឆ្នាំ =_____ថ្ងៃ

១៨. ១ ឆ្នាំ =_____សប្តាហ៏

១៩. ១ ទស្សវត្សរ៏ =_____ឆ្នាំ

២០. ១ សតវត្សរ៏ =_____ឆ្នាំ

២១. ១ ដុល្លា =_____ភេននី

២២. ១ ដុល្លា =_____នីកែល

២៣. ១ ដុល្លា =_____ដាម

២៤. ១ ដុល្លា =_____ចតុភាគ

២៥. ទឹកពុះ =_____F°

២៦. ទឹកកក =_____ F°

២៧. ទឹកពុះ =_____C°

២៨. ទឹកកក =_____ C°

**កំណត់ចំណាំ:** ប្រសិនបើអ្នកផ្តល់ឧបករណ៏វាស់វែងអោយកូនអ្នក សំរាប់ប្រើប្រាស់ឯកតាជាមូលដ្ឋាននៃរង្វាស់រង្វាល់ ដើម្បីជួយកូនអ្នកបំពេញបញ្ចប់នៅលើទំព័រនៃការប្តូររង្វាស់រង្វាល់នេះ។

- បន្ទាត់: អ៊ិញ យ៉ាត សង្ទីម៉ែត ម៉ែត
- រង្វាស់ខាប់: អ៊ាន់ ខាប់ ភិន ចតុភាគ?មួយភាគបួន កាឡុង លីត
- រង្វាស់ទំងន់: អ៊ាន់ ផោន ក្រាម គីឡូក្រាម
- ម៉ោង: ឌីឃីថលឬលោតលេខ និងនាឡិកាជាលេខ
- ប្រតិទិន
- រូបិយប័ណ្ណ: កាក់ភេននី នីកែល កាក់ឌីម ចតុភាគ?មួយភាគបួន ដុល្លា
- ទែម៉ូម៉ែត: ហ្វារីនហៃ និងសែលស្យូស

អ្នកគួរបង្ហាញដល់កូនអ្នកនូវការប្រើប្រាស់ញឹកញាប់អក្សរកាត់ និងនិមិត្តសញ្ញាជាទូទៅនៃស្តង់ដាឯកតាឈ្មោះរង្វាស់រង្វាល់៖

| | | | | | |
|---|---|---|---|---|---|
| អ៊ិញបា | in. ឬ ” | សង្ទីម៉ែតបា | cm | ហ្វារិនហៃបា | F |
| ហ្វូត៖ | ft. ឬ ’ | ម៉ែត៖ | m | សែលស្យូស៖ | C |
| យ៉ាត៖ | yd. | គីឡូម៉ែត៖ | km | | |
| អ៊ោន់បា | oz. | មីលីម៉ែត៖ | ml | | |
| ផោន៖ | lb. | លីត៖ | l | | |
| នាទី៖ | mn | ក្រាម៖ | g | | |
| ម៉ោង៖ | hr. | គីឡូក្រាម៖ | kg | | |
| ឆ្នាំ៖ | yr. | | | | |

**ចម្លើយ**

១. ១ ហ្វូត = 12 អ៊ិញ

២. ១ យ៉ាត= 36 អ៊ិញ

៣. ១ យ៉ាត = 3 ហ្វីត

៤. ១ ម៉ែត = 100 សង្ទីម៉ែត

៥. ១ គីឡូម៉ែត = 1,000 ម៉ែត

៦. ១ខាប់ = 8 អ៊ោន់

៧. ១ ភីន = 2 ខាប់

៨. ១ ចតុភាគ = 2 ភីន

៩. ១ កាឡុង = 4 ចតុភាគ(បួនភាគបួន)

១០. ១ លីត = 1,000 មីលីលីត

១១. ១ ផោន = 16 អ៊ោន់

១២. ១ គីឡូក្រាម = 1,000 ក្រាម

១៣. ១ នាទី = 60 វិនាទី

១៤. ១ ម៉ោង = 60 នាទី

១៥. ១ ថ្ងៃ = 24 ម៉ោង

១៦. ១ សប្តាហ៍ = 7 ថ្ងៃ

១៧. ១ ឆ្នាំ = 365 ថ្ងៃ (ឆ្នាំលោតផ្លោះមាន ៣៦៦ ថ្ងៃ)

១៨. ១ ឆ្នាំ = 52 សប្តាហ៍

១៩. ១ សតវត្សរ៍ = 10 ឆ្នាំ

២០. ១ សតវត្សរ៍= 100 ឆ្នាំ

២១. ១ ដុល្លា = 100 ភេននី

២២. ១ ដុល្លា = 20 នីកែល

២៣. ១ ដុល្លា = 10 ឌីម

២៤. ១ដុល្លា = 4 ចតុភាគ(បួនភាគបួន)

២៥. ទឹកពុះ = 212° F

២៦. ទឹកកំពុងកក = 32° F

២៧. ទឹកពុះ = 100°C

២៨. ទឹកកំពុងកក= 0° C

# ឯកតាប្រវែង

## ឯកតារង្វាស់ប្រវែង

10 (mm) = 1 (សម)

10 សង្ទីម៉ែត= 1 ដេស៊ីម៉ែត(ដម)

10 ដេស៊ីម៉ែត = 1 (ម)

1,000 ម៉ែត= 1 គីឡូម៉ែត(គម)

x 10 x 10 x 10 x 10 x 10 x 10

| | | | | | | |
|---|---|---|---|---|---|---|
| គីឡូម៉ែត | ហិចតូម៉ែត | ដេកាម៉ែត | ម៉ែត | ដេស៊ីម៉ែត | សង្ទីម៉ែត | មីលីម៉ែត |

÷ 10 ÷ 10 ÷ 10 ÷ 10 ÷ 10 ÷ 10

## ÉktargVas´Tmán´

1,000 មីលីក្រាម(មល) = 1 ក្រាម (ក)

1,000 ក្រាម= 1 គីឡូក្រាម(គក)

1,000 គីឡូក្រាម= 1 តោន(ត)

x 10 x 10 x 10 x 10 x 10 x 10

| | | | | | | |
|---|---|---|---|---|---|---|
| គីឡូក្រាម | ហិចតូក្រាម | ដេកាក្រាម | ក្រាម | ដេស៊ីក្រាម | សង្ទីក្រាម | មីលីក្រាម |

÷ 10 ÷ 10 ÷ 10 ÷ 10 ÷ 10 ÷ 10

## ឯកតារង្វាស់ចំណុះ

1,000 មីលីលីត(មល) = 1 លីត(ល)

10 ដេសីលីត(ដល) = 1 លីត(ល)

x 10 x 10 x 10

| | | | |
|---|---|---|---|
| លីត | ដេស៊ីលីត | សង្ទីលីត | មីលីលីត |

÷ 10 ÷ 10 ÷ 10

# ប្រមាណវិធីគុណពិត
## សិស្សទាំងអស់ត្រូវចងចាំ

| សូន្យ | មួយ | ពីរ | ប្រាំ | ដប់ |
|---|---|---|---|---|
| 0 x 0 = 0 | 1 x 0 = 0 | 2 x 0 = 0 | 5 x 0 = 0 | 10 x 0 = 0 |
| 0 x 1 = 0 | 1 x 1 = 1 | 2 x 1 = 2 | 5 x 1 = 5 | 10 x 1 = 10 |
| 0 x 2 = 0 | 1 x 2 = 2 | 2 x 2 = 4 | 5 x 2 = 10 | 10 x 2 = 20 |
| 0 x 3 = 0 | 1 x 3 = 3 | 2 x 3 = 6 | 5 x 3 = 15 | 10 x 3 = 30 |
| 0 x 4 = 0 | 1 x 4 = 4 | 2 x 4 = 8 | 5 x 4 = 20 | 10 x 4 = 40 |
| 0 x 5 = 0 | 1 x 5 = 5 | 2 x 5 = 10 | 5 x 5 = 25 | 10 x 5 = 50 |
| 0 x 6 = 0 | 1 x 6 = 6 | 2 x 6 = 12 | 5 x 6 = 30 | 10 x 6 = 60 |
| 0 x 7 = 0 | 1 x 7 = 7 | 2 x 7 = 14 | 5 x 7 = 35 | 10 x 7 = 70 |
| 0 x 8 = 0 | 1 x 8 = 8 | 2 x 8 = 16 | 5 x 8 = 40 | 10 x 8 = 80 |
| 0 x 9 = 0 | 1 x 9 = 9 | 2 x 9 = 18 | 5 x 9 = 45 | 10 x 9 = 90 |
| 0 x 10 = 0 | 1 x 10 = 10 | 2 x 10 = 20 | 5 x 10 = 50 | 10 x 10 = 100 |

| បី | បួន | ប្រាំបួន | ការេគត់ | មេលេខពិបាក |
|---|---|---|---|---|
| 3 x 0 = 0 | 4 x 0 = 0 | 9 x 0 = 0 | 0 x 0 = 0 | 6 x 7 = 42 |
| 3 x 1 = 3 | 4 x 1 = 4 | 9 x 1 = 9 | 1 x 1 = 1 | 7 x 6 = 42 |
| 3 x 2 = 6 | 4 x 2 = 8 | 9 x 2 = 18 | 2 x 2 = 4 | 6 x 8 = 48 |
| 3 x 3 = 9 | 4 x 3 = 12 | 9 x 3 = 27 | 3 x 3 = 9 | 8 x 6 = 48 |
| 3 x 4 = 12 | 4 x 4 = 16 | 9 x 4 = 36 | 4 x 4 = 16 | 7 x 8 = 56 |
| 3 x 5 = 15 | 4 x 5 = 20 | 9 x 5 = 45 | 5 x 5 = 25 | 8 x 7 = 56 |
| 3 x 6 = 18 | 4 x 6 = 24 | 9 x 6 = 54 | 6 x 6 = 36 | |
| 3 x 7 = 21 | 4 x 7 = 28 | 9 x 7 = 63 | 7 x 7 = 49 | |
| 3 x 8 = 24 | 4 x 8 = 32 | 9 x 8 = 72 | 8 x 8 = 64 | |
| 3 x 9 = 27 | 4 x 9 = 36 | 9 x 9 = 81 | 9 x 9 = 81 | |
| 3 x 10 = 30 | 4 x 10 = 40 | 9 x 10 = 90 | 10 x 10 = 100 | |

### យុទ្ធសាស្ត្រនៃវិធីគុណ

| | |
|---|---|
| សូន្យ | លេខណាមួយក៏ដោយគុណនឹងសូន្យគឺស្មើនឹងសូន្យ |
| មួយ | លេខណាមួយក៏ដោយគុណនឹងមួយគឺស្មើនឹងលេខនោះ |
| ពីរ | រំលងរាប់លេខគុណនឹងពីរ(ពីរ បួន ប្រាំមួយ ប្រាំបី...) |
| ប្រាំ | រំលងរាប់លេខគុណនឹងប្រាំ(ប្រាំ ដប់ ដប់ប្រាំ ម្ភៃ...) |
| ដប់ | រំលងរាប់លេខគុណនឹងដប់(ដប់ ម្ភៃ សាមសិប សែសិប...) |
| បី | រំលងរាប់លេខគុណនឹងបី(បី ប្រាំមួយ ប្រាំបួន ដប់ពីរ...) |
| បួន | គុណលេខនឹងពីរ ពីរពីរដង និងបូក (ឧទា. 4 x 7: 2 x 7 = 14, 2 x 7 = 14 និង 14 + 14 = 28) |
| ប្រាំបួន | គូររង្វង់លេខដែលគុណនឹងប្រាំបួន។ សរសេរលេខដែល លេខមួយតូចជាងលេខ នៅក្នុងរង្វង់ (ក្នុងខ្ទង់ដប់)។ បន្ទាប់មកសរសេរលេខដែលបំរុងនឹងបូកបន្ថែម ឲ្យបានប្រាំបួន (ក្នុងខ្ទង់រាយ)។ (ឧទា. 9 x 7: 6តូចជាង 7 សរសេរ 6។ 6 + 3 = 9 សរសេរ 3។ ចម្លើយគឺ: 9 x 7 = 63)។ |
| ការេល្អឥតខ្ចោះ | លេខគុណនឹងខ្លួនឯង: 3 x 3 = 9  3 3 |

# LBUSD

## ប៉ាន់ស្មានចំនួនទសភាគ

## ផ្នែក ក

### ចំនួនទសភាគ

**1.** សរសេរទសភាគលេខបីខ្ទង់ភាគពាន់

**A** 0.3　　**C** 0.03

**B** 0.003　　**D** 0.0003

**2.** សរសេរលេខ 0.07 ជាប្រភាគ

**A** $\frac{7}{10,000}$　　**C** $\frac{7}{100}$

**B** $\frac{7}{1,000}$　　**D** $\frac{7}{10}$

**3.** តើលេខណាមួយបង្ហាញចំនួនទសភាគពីធំបំផុតទៅតូចបំផុត?

**A** 3.005, 3.04, 3.1　　**C** 3.04, 3.1, 3.005

**B** 3.1, 3.04, 3.005　　**D** 3.1, 3.005, 3.04

**4.** តើលេខ 0.968 បង្គត់ទៅគៀកទសភាគភាគរយមានប៉ុន្មាន?

**A** 1.0　　**C** 0.96

**B** 0.9　　**D** 0.97

**5.** សរសេរប្រភាគ $\frac{23}{100}$ ជាចំនួនទសភាគ

**A** 2.3　　**C** 0.23

**B** 0.023　　**D** 100.23

## ផ្នែក ខ

### វិធីបូកចំនួនទសភាគ

**6.** តើការប៉ាន់ស្មានលេខដែលល្អបំផុតប៉ុន្មាន?

0.8 + 2 = **?**

**A** 10　　**C** 2

**B** 3　　**D** 1

**7.** បូកចំនួនទសភាគ: 32.26 + 1.132 =

**A** 43.58　　**C** 4.358

**B** 33.392　　**D** 3.3392

**8.** បូកចំនួនទសភាគ: 2.32 + 1.7 =

**A** 3.02　　**C** 3.39

**B** 2.49　　**D** 4.02

**9.** Add: 0.32 + 5 =

**A** 0.325　　**C** 5.32

**B** 0.82　　**D** 32.5

**10.** ប៉ាទ្រិចមានកំដៅសីតុណ្ហភាពធម្មតា 98.6° F.។ ប៉ុន្តែប៉ាទ្រិចឈឺ និងក្តៅខ្លួន។សីតុណ្ហភាពបានកើន 3.6° F លើសពីធម្មតា។ តើប៉ាទ្រិចមានកំដៅសីតុណ្ហភាពប៉ុន្មានអីឡូវនេះ?

**A** 101.4°F　　**C** 102.4°F

**B** 98.6°F　　**D** 94.8°F

បន្ត

long beach unified school district

# LBUSD

## ប៉ាន់ស្មានចំនួនទសភាគ

### ផ្នែក គ

ប្រមាណវិធីដកចំនួនទសភាគ

**11.** តើការប៉ាន់ស្មានលេខដែលល្អបំផុតប៉ុន្មាន? 4 – 0.9 = ?

**A** 4 **C** 3

**B** 4.9 **D** 3.9

**12.** ដកចំនួនគត់នឹងទសភាគ: 7 – 0.05 =

**A** 6.95 **C** 2

**B** 6.5 **D** 0.95

**13.** ដកចំនួនទសភាគនឹងទសភាគ: 2.38 – 1.67 =

**A** 1.31 **C** 1.71

**B** 0.71 **D** 1.29

**14.** ដកចំនួនទសភាគនឹងទសភាគ: 2.003 – 0.93 =

**A** 1.100 **C** 2.010

**B** 1.073 **D** 1.173

**15.** មីហ្គែលទិញអាវមួយថ្លៃ $18.65។ គាត់ឲ្យលុយទៅគេក្រដាស $20 ។ តើគេអាប់លុយឲ្យគាត់វិញប៉ុន្មាន?

**A** $1.35 **C** $2.45

ព ៛១។៤៥ ឌ ៛២។៦៥

### ផ្នែក ឃ

ប្រមាណគុណចំនួនទសភាគ

**16.** តើការប៉ាន់ស្មានលេខដែលល្អបំផុតប៉ុន្មាន? 6.03 x 1.9 = ?

**A** 6 **C** 8

**B** 10 **D** 12

**17.** គុណទសភាគនឹងចំនួនគត់: 1.09 x 100 =

**A** 1,090 **C** 10.9

**B** 109 **D** 0.0109

**18.** គុណចំនួនគត់នឹងទសភាគ 3 x 0.16 =

**A** 48 **C** 3.6

**B** 4.8 **D** 0.48

**19.** គុណចំនួនទសភាគនឹងទសភាគ 0.15 x 0.02 =

**A** 0.003 **C** 3

**B** 0.03 **D** 30

**20.** ណាតាលីទិញទឹកផ្លែឈើប្រាំមួយដបដោយក្នុងមួយដបថ្លៃ $0.89 ។ តើទឹកផ្លែឈើទាំងអស់ថ្លៃប៉ុន្មាន?

**A** $53.40 **C** $5.25

**B** $5.34 **D** $0.95

បន្ត

# LBUSD
# ប៉ាន់ស្មានចំនួនទសភាគ

## ផ្នែក ង

ប្រមាណវិធីចែកចំនួនទសភាគ

**21.** តើការប៉ាន់ស្មានលេខដែលល្អបំផុត $5.8 \div 2.1 =$ ប៉ុន្មាន?

**A** 4 **C** 3

**B** 5 **D** 12

**22.** ចែកចំនួនទសភាគនឹងចំនួនគត់: $0.3 \div 100 =$

**A** 0.003 **C** 3

**B** 0.03 **D** 30

**23.** ចែកចំនួនទសភាគនឹងចំនួនគត់: $1.6 \div 40 =$

**A** 40 **C** 0.4

**B** 0.004 **D** 0.04

**24.** ចែកចំនួនទសភាគនឹងទសភាគ: $0.005 \div 0.4 =$

**A** 1.25 **C** 0.0125

**B** 0.125 **D** 0.00125

**25.** ការហៅទូរស័ព្ទចេញថ្លៃ $7.50 ក្នុង 25នាទី។ តើការហៅចេញក្នុងមួយនាទីថ្លៃប៉ុន្មាន។

**A** $0.30 **C** $3.33

**B** $30.00 **D** $0.03

បញ្ឈប់

long beach unified school district

# LBUSD

## ប៉ាន់ស្មានចំនួនទសភាគ

## ចម្លើយ

| ផ្នែក ក | ផ្នែក ខ | ផ្នែក គ | ផ្នែក ឃ | ផ្នែក ង |
|---|---|---|---|---|
| 1. B | 6. B | 11. C | 16. D | 21. C |
| 2. C | 7. B | 12. A | 17. B | 22. A |
| 3. B | 8. D | 13. B | 18. D | 23. D |
| 4. D | 9. C | 14. B | 19. A | 24. C |
| 5. C | 10. C | 15. A | 20. B | 25. A |

long beach unified school district **LBUSD**

# ការប៉ាន់ស្មានប្រភាគ

## ផ្នែក ក

### កត្តាចំនួន និងប្រមាណវិធីគុណ

**3.** តើលេខណាមិនមែនកត្តានៃចំនួន 48 ?

**A** 4 **C** 12

**B** 10 **D** 16

**4.** តើលេខប៉ុន្មានជាចំនួនបឋម?

**A** 32 **C** 29

**B** 65 **D** 57

**5.** តើលេខប៉ុន្មានជាកត្តាបឋមនៃ 56 ?

**A** 2 x 2 x 2 x 7 **C** 8 x 7

**B** 4 x 14 **D** 2 x 3 x 3 x 3

**4.** តើលេខប៉ុន្មានជាកត្តារួមធំបំផុតនៃ 36 និង 54?

**A** 12 **C** 6

**B** 9 **D** 18

**5.** តើលេខប៉ុន្មានជាផលគុណរួមតូចបំផុតនៃ 24 និង 36?

**A** 12 **C** 60

**B** 864 **D** 72

## ផ្នែក ខ

### បញ្ញត្តិនៃប្រភាគ

**6.** ប្រភាគប៉ុន្មានប្រាប់ពីចំនួនម្លប់ផ្កាយ?



**A** $\frac{5}{9}$ **C** $\frac{9}{9}$

**B** $\frac{1}{9}$ **D** $\frac{4}{9}$

**7.** តើប្រភាគប៉ុន្មានសមមូលនឹងប្រភាគ $\frac{2}{5}$ ?

**A** $\frac{2}{10}$ **C** $\frac{6}{10}$

**B** $\frac{8}{20}$ **D** $\frac{12}{35}$

**8.** តើប្រភាគប៉ុន្មានមានទំរង់ងាយបំផុត?

**A** $\frac{9}{10}$ **C** $\frac{8}{12}$

**B** $\frac{4}{16}$ **D** $\frac{7}{14}$

ត

# LBUSD

# ការប៉ាន់ស្មានប្រភាគ

**9.** តើប្រភាគប៉ុន្មានបង្ហាញសមមូលប្រភាគនៃ $\frac{3}{4}$ និង $\frac{2}{3}$ ដោយប្រើភាគបែងរួមតូចបំផុត?

**A** $\frac{9}{12}; \frac{8}{12}$

**B** $\frac{18}{24}; \frac{16}{24}$

**C** $\frac{6}{8}; \frac{4}{8}$

**D** $\frac{3}{12}; \frac{3}{12}$

# ផ្នែក គ

## ប្រភាគ និងចំនួនចំរុះ

**10.** ប្រភាគប៉ុន្មានបង្ហាញប្រភាគមិនសុទ្ធនៃ ចំនួនចំរុះ $5\frac{4}{7}$?

**A** $\frac{16}{7}$

**B** $\frac{39}{7}$

**C** $\frac{35}{7}$

**D** $\frac{140}{7}$

**11.** សរសេរប្រភាគ $\frac{46}{9}$ ជាចំនួនចំរុះ។

**A** $4\frac{6}{9}$

**B** $5\frac{1}{9}$

**C** $1\frac{5}{9}$

**D** $9\frac{1}{5}$

**12.** តើប្រភាគមួយណាត្រូវ?

**A** $\frac{2}{3} > \frac{3}{4}$

**B** $\frac{4}{5} = \frac{8}{15}$

**C** $\frac{5}{7} < \frac{7}{8}$

**D** $\frac{11}{20} > \frac{3}{5}$

# ផ្នែក ឃ

## វិធីបូក និងដកប្រភាគ

**13.** តើការប៉ាន់ស្មានចំនួនចំរុះ $1\frac{3}{8} + 2\frac{5}{6}$ ល្អបំផុតដូចខាងក្រោមនេះប៉ុន្មាន ?

**A** 1

**B** 2

**C** 3

**D** 4

**14.** រកទំរង់ប្រភាគ $\frac{5}{12} + \frac{3}{12}$ ងាយបំផុត។

**A** $\frac{2}{3}$

**B** $\frac{3}{4}$

**C** $\frac{8}{24}$

**D** $\frac{8}{12}$

**15.** រកទំរង់ប្រភាគ $\frac{3}{4} + \frac{1}{6}$ ងាយបំផុត។

**A** $\frac{4}{10}$

**B** $\frac{2}{5}$

**C** $\frac{11}{12}$

**D** $\frac{22}{24}$

**16.** រកទំរង់ប្រភាគ $\frac{7}{8} - \frac{3}{4}$ ងាយបំផុត។

**A** $\frac{1}{8}$

**B** $\frac{1}{4}$

**C** $\frac{4}{4}$

**D** $\frac{1}{2}$

ត

long beach unified school district **LBUSD**

# ការប៉ាន់ស្មានប្រភាគ

**17.** រកទំរង់ចំនួនចំរុះ $8\frac{1}{4} - 4\frac{3}{4}$ ងាយបំផុត។

**A** $3\frac{1}{4}$ **C** $4\frac{1}{4}$

**B** $3\frac{1}{2}$ **D** $4\frac{1}{2}$

**18.** រកទំរង់ចំនួនចំរុះ $3\frac{2}{3} - 2\frac{1}{2}$ ងាយបំផុត។

**A** $1\frac{1}{3}$ **C** $1\frac{1}{2}$

**B** $1\frac{1}{6}$ **D** $1\frac{1}{5}$

## ផ្នែក ង

### វិធីគុណប្រភាគ

**19.** តើការប៉ាន់ស្មានចំនួនចំរុះ $3\frac{7}{8} \times 4\frac{4}{9}$ ល្អបំផុតប៉ុន្មាន?

**A** 8 **C** 16

**B** 12 **D** 20

**20.** តើប្រភាគ $\frac{5}{9} \times \frac{1}{3}$ ក្នុងទំរង់ណាងាយបំផុត។

**A** $\frac{5}{27}$ **C** $1\frac{2}{3}$

**B** $\frac{1}{2}$ **D** $\frac{15}{9}$

**21.** រកទំរង់ $9 \times \frac{2}{3}$ ងាយបំផុត។

**A** $\frac{11}{3}$ **C** 6

**B** $9\frac{2}{3}$ **D** 18

## ផ្នែក ច

### វិធីចែកប្រភាគ

**22.** ប៉ាន់ស្មាន: $14\frac{3}{4} \div 2\frac{7}{10}$

**A** 3 **C** 7

**B** 5 **D** 12

**23.** រក $8 \div \frac{2}{5}$ ក្នុងទំរង់ងាយបំផុត។

**A** $\frac{1}{20}$ **C** 20

**B** $3\frac{1}{5}$ **D** 40

**24.** រក $\frac{9}{10} \div \frac{4}{5}$ ក្នុងទំរង់ងាយបំផុត។

**A** $\frac{18}{25}$ **C** $1\frac{1}{8}$

**B** $\frac{8}{9}$ **D** $1\frac{1}{9}$

**25.** រក $\frac{3}{8} \div 12$ ក្នុងទំរង់ងាយបំផុត។

**A** $\frac{1}{9}$ **C** 9

**B** $\frac{1}{32}$ **D** 32

# LBUSD

# ការប៉ាន់ស្មានប្រភាគ

## ចម្លើយ

| ផ្នែកA | ផ្នែក B | ផ្នែកC | ផ្នែកD | ផ្នកE | ផ្នែកF |
|---|---|---|---|---|---|
| 1. B | 6. D | 10. B | 13. D | 19. C | 22. B |
| 2. C | 7. B | 11. B | 14. A | 20. A | 23. C |
| 3. A | 8. A | 12. C | 15. C | 21. C | 24. C |
| 4. D | 9. A | | 16. A | | 25. B |
| 5. D | | | 17. B | | |
| | | | 18. B | | |